ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ក្រសួងសាធារណការ និង ដឹកជញ្ជូន

MINISTRY OF PUBLIC WORKS AND TRANSPORT

# គោលការណ៍ណែនាំ

សម្រាប់

# ប្រតិបត្តិការ និងថែទាំបណ្តាញលូ
# ប្រព័ន្ធទឹកកខ្វក់ក្នុងព្រះរាជាណាចក្រកម្ពុជា

# Guideline for Operation and Maintenance of Sewerage Networks

2024

# គោលការណ៍ណែនាំស្តីពី
# ប្រតិបត្តិការ និងថែទាំបណ្តាញលូ
# ប្រព័ន្ធទឹកកខ្វក់ក្នុងព្រះរាជាណាចក្រកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ: ០៤១ សក.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ ប្រតិបត្តិការ និងថែទាំបណ្តាញលូប្រព័ន្ធទឹកកខ្វក់ក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ គោលការណ៍ណែនាំសម្រាប់ ប្រតិបត្តិការ និងថែទាំបណ្តាញលូប្រព័ន្ធទឹកកខ្វក់ក្នុងព្រះរាជាណាចក្រកម្ពុជា (Guidelines for Operation and Maintenance of Sewerage Networks) បោះពុម្ពឆ្នាំ២០២៤។

**ប្រការ២.-**

គោលការណ៍ណែនាំនេះប្រើប្រាស់ជាទូទៅ សម្រាប់ការងារប្រតិបត្តិការ និងថែទាំបណ្តាញលូប្រព័ន្ធទឹកកខ្វក់នៅទូទាំងប្រទេស។

**ប្រការ៣.-**

រាល់ការកែប្រែ ឬបន្ថែមទៅលើខ្លឹមសារបច្ចេកទេសទាំងឡាយ ដែលមានចែងនៅក្នុងគោលការណ៍ណែនាំ ដូចមានចែងនៅក្នុងប្រការ១ ខាងលើ អាចអនុវត្តទៅបានលុះត្រាតែមានការណែនាំជាថ្មីរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន ប្រធាននាយកដ្ឋាន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ប្រធានអង្គភាពក្រោមឱវាទក្រសួង និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕ Sal.

ថ្ងៃ ចន្ទ ៧ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី-ខេត្ត

  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ ៤

  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អារម្ភកថា

ផ្អែកលើបទពិសោធន៍នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល ព្រមទាំងទស្សនវិស័យ និងគោលនយោបាយអភិវឌ្ឍន៍វិស័យទឹកស្អាត និងអនាម័យ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃនិងស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅតែបន្តផ្តល់អាទិភាពខ្ពស់ដល់វិស័យទឹកស្អាត និងអនាម័យ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ មុំទី៤ ចំណុចទី៣ ដោយផ្តោតលើការរៀបចំផែនការមេអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជន ការគ្រប់គ្រងទុកដាក់ និងកែច្នៃសំរាម ប្រព័ន្ធលូរំដោះទឹកភ្លៀង ប្រព័ន្ធចម្រោះ និងប្រព្រឹត្តកម្មទឹកកខ្វក់។

នាពេលបច្ចុប្បន្ន ស្របគ្នាជាមួយនឹងសន្ទុះនៃការអភិវឌ្ឍដែលមានការលូតលាស់យ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ កំណើនប្រជាជនដែលបានរស់នៅតាមទីក្រុង និងទីប្រជុំជនធំៗ មានការកើនឡើងយ៉ាងច្រើន ជាសមាមាត្រនាំឱ្យការបញ្ចេញទឹកកខ្វក់មានបរិមាណច្រើនទៅតាមនោះដែរ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រងទឹកកខ្វក់។ ក្រសួងសាធារណការ និងដឹកជញ្ជូន បាននិងកំពុងតែធ្វើការងារយ៉ាងសកម្ម និងមមាញឹក ជាមួយគ្រប់ភាគីពាក់ព័ន្ធនានា រួមទាំងស្ថាប័នជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍សំខាន់ៗ ក្នុងការស្វះស្វែងរកនូវដំណោះស្រាយចាំបាច់ រួមទាំងការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ការរៀបចំនូវគោលនយោបាយយុទ្ធសាស្ត្រ ឯកសារបច្ចេកទេស និងបទដ្ឋានគតិយុត្តចាំបាច់ សំដៅធ្វើយ៉ាងណាឱ្យការគ្រប់គ្រងទឹកកខ្វក់ និងសំណល់រឹងនេះអាចធ្វើទៅបានប្រកបដោយបរិយាបន្ន មានប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។

នៅក្នុងបរិបទនេះ ការអភិវឌ្ឍមិនត្រឹមតែត្រូវការហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវការនូវដំណើរការប្រតិបត្តិ និងការថែទាំ ផ្អែកលើមូលដ្ឋានច្បាស់លាស់ ការអប់រំក្នុងសហគមន៍ ការយល់ដឹងពីលក្ខណៈបច្ចេកទេស និងការអនុវត្តផ្នែកច្បាប់។ លើសពីនេះទៅទៀតបើគ្មានការយកចិត្តទុកដាក់ផ្នែកប្រតិបត្តិការ និងថែទាំត្រឹមត្រូវនេះទេ ហេដ្ឋារចនាសម្ព័ន្ធអាចនឹងងាយខូចខាតដល់កម្រិតមួយដែលមិនអាចជួសជុលបាន ឬមិនអាចប្រើប្រាស់ទៅតាមសក្តានុពលពេញលេញរបស់វាបាន។ ដូច្នេះវាជាការចាំបាច់តម្រូវឱ្យមានប្រតិបត្តិករ ដែលមានជំនាញបច្ចេកទេសច្បាស់លាស់ និងការបណ្តុះបណ្តាល ហើយមន្ត្រីរាជរដ្ឋាភិបាលចាំបាច់ត្រូវគ្រប់គ្រងដំណើរការថែទាំ ជួសជុល ត្រួតពិនិត្យ និងអង្កេតតាមដានលើប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធទឹកកខ្វក់នេះ។

ក្រសួងសាធារណការ និងដឹកជញ្ជូន បានសម្រេចរៀបចំចងក្រងសៀវភៅ **"គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការ និងថែទាំបណ្តាញលូប្រព័ន្ធទឹកកខ្វក់ក្នុងព្រះរាជាណាចក្រកម្ពុជា** (Guidelines for Operation and Maintenance of Sewerage Networks)" ដោយសហការជាមួយ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ដែលសមស្របទៅតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា។ សៀវភៅគោលការណ៍ណែនាំខាងលើនេះ ត្រូវកំណត់ប្រើប្រាស់ជាឯកសារគោលសម្រាប់ការប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទឹកកខ្វក់នៅក្នុងប្រទេសកម្ពុជា ដើម្បីឱ្យការប្រើប្រាស់ប្រកបដោយនិរន្តរភាព។

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) និងក្រុមការងារបច្ចេកទេសទាំងអស់ដែលបានយកចិត្តទុកដាក់ខិតខំប្រឹងប្រែងចូលរួមចំណែកអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ក្នុងការរៀបចំចងក្រងនូវសៀវភៅ "**គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការ និងថែទាំបណ្តាញលូប្រព័ន្ធទឹកកខ្វក់ក្នុងព្រះរាជាណាចក្រកម្ពុជា** (Guidelines for Operation and Maintenance of Sewerage Networks)" នេះឱ្យបានចេញជារូបរាងឡើង សម្រាប់ជាគុណប្រយោជន៍ ដើម្បីចូលរួមចំណែកជួយពង្រឹងការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ឱ្យបានកាន់តែប្រសើរឡើង។

ថ្ងៃ ចន្ទ ២កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ប៉េង ពោធិ៍នា**

# បុព្វកថា

ក្រសួងសាធារណការ និងដឹកជញ្ជូន បាននឹងកំពុងខិតខំ ប្រឹងប្រែង យកចិត្តទុកដាក់ខ្ពស់ ដោយសហការជាមួយក្រសួងស្ថាប័នជាតិពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍សំខាន់នានា ក្នុងការជំរុញការអភិវឌ្ឍវិស័យប្រព័ន្ធទឹកកខ្វក់ និងអនាម័យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងជីវភាពរស់នៅបច្ចុប្បន្ន គោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល និងផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ របស់អង្គការសហប្រជាជាតិ។ ដោយឡែកនៅក្នុងគម្រោងអភិវឌ្ឍន៍សមត្ថភាព លើការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ដែលជាគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ក្រុមការងាររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមអ្នកជំនាញបច្ចេកទេស បានសហការគ្នារៀបចំសៀវភៅ "**គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការ និងថែទាំបណ្តាញលូ** (Guideline for Operation and Maintenance of Sewerage Networks)" កំណែទី២។

សៀវភៅគោលការណ៍ណែនាំនេះត្រូវបានបែងចែងជា៦ជំពូក សម្រាប់ប្រតិបត្តិការ និងថែទាំបណ្តាញលូ៖ ជំពូកទី១ និយាយអំពីទំហំការងារ និងប្រភេទការងារ ជំពូកទី២ និយាយអំពីការងារត្រួតពិនិត្យ ជំពូកទី៣ និយាយអំពីការថែទាំ ជំពូកទី៤ និយាយអំពីការការពារ និងការកែលម្អ ជំពូកទី៥ និយាយអំពីសុវត្ថិភាពការងារ និងជំពូកទី៦ សង្ខេបអំពីដំណើរការប្រតិបត្តិការ និងថែទាំ។

ការរៀបចំសៀវភៅគោលការណ៍ណែនាំបច្ចេកទេសខាងលើនេះ គឺជាការបំពេញបន្ថែមចំពោះតម្រូវការបច្ចេកទេសសំខាន់ៗ ចាំបាច់សម្រាប់ការងារប្រតិបត្តិ និងថែទាំប្រព័ន្ធទឹកកខ្វក់។ ក្រសួងសាធារណការ និងដឹកជញ្ជូន ស្វាគមន៍ទទួលយកនូវធាតុចូល មតិយោបល់ ដើម្បីយកមកធ្វើការសិក្សាកែតម្រូវ និងបំពេញបន្ថែម ធ្វើយ៉ាងណាដើម្បីឱ្យសៀវភៅគោលការណ៍ណែនាំបច្ចេកទេសនេះកាន់តែមានសុក្រឹតភាព សម្រាប់ការប្រើប្រាស់នៅក្នុងការបោះពុម្ពផ្សាយនាពេលក្រោយ។

**ក្រុមការងារបច្ចេកទេស**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅគោលការណ៍ណែនាំនេះ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ត្រូវបានបង្កើតឡើងដោយ នាយកដ្ឋានស្រាវជ្រាវប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (Global Green Growth Institute)។ សៀវភៅគោលការណ៍ណែនាំនេះ គឺផ្អែកទៅលើសៀវភៅមគ្គុទេសក៍ ស្តីពី ប្រព័ន្ធលូបង្ហូរទឹក និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដែលបោះពុម្ពដោយ ក្រសួងអភិវឌ្ឍន៍ទីក្រុងនៃប្រទេសឥណ្ឌា ដែលសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency)។ ផ្នែកមួយចំនួននៅក្នុងសៀវភៅណែនាំនេះ ដែលពាក់ព័ន្ធត្រូវបានយកមកកែសម្រួលស្របទៅតាមបរិបទកម្ពុជា។

ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងបុគ្គលិកនៃអង្គការដៃគូរអភិវឌ្ឍន៍ខាងក្រោម បានចូលរួមចំណែកដល់ការរៀបចំគោលការណ៍ណែនាំបច្ចេកទេសនេះ មានរាយនាមដូចខាងក្រោម៖

**រៀបរៀងដោយ៖**

**ក. អគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន**

| | |
|---|---|
| ១. ឯកឧត្តម ថៅ សុភៈភិបាល | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ២. លោកស្រី ជួង ដានី | អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ៣. លោក សួន និមល | អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ៤. លោក ពូ ម៉ានិត | ប្រធាននាយកដ្ឋានសរុប និងព័ត៌មាន នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ៥. លោក អ៊ឹម វិបុល | ប្រធាននាយកដ្ឋានស្រាវជ្រាវប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ៦. លោក ហេង ភូរី | ប្រធាននាយកដ្ឋានសាងសង់ និងថែទាំប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ៧. លោក នង សម្បត្តិវឌ្ឍនា | អនុប្រធាននាយកដ្ឋានសាងសង់ និងថែទាំប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| ៨. លោក លន់ ហេង | អនុប្រធាននាយកដ្ឋានសរុប និងព័ត៌មាន នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |

៩. លោក ឆេង សុវណ្ណឌី — ប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានស្រាវជ្រាវប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់

១០. លោក យឹម សាន់ដេ — ប្រធានការិយាល័យថែទាំ នៃនាយកដ្ឋានសាងសង់ និងថែទាំប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់

១១. កញ្ញា ស៊ិន ស៊ីវលីង — អនុប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានស្រាវជ្រាវប្រព័ន្ធចម្រោះទឹកកខ្វក់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់

១២. លោក នី ម៉ារ៉ាឌី — មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់

១៣. លោក សុផល រ៉ាទិត្យា — មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់

**ខ. វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល** (Global Green Growth Institute)

១. លោកស្រី Shomi Kim — ប្រធានតំណាងប្រទេសកម្ពុជា

២. លោក Ankit Bhatt — អ្នកដឹកនាំកម្មវិធីសេដ្ឋកិច្ចចក្រា និងសំណល់ប្រចាំតំបន់អាស៊ី

៣. លោកស្រីបណ្ឌិត ជា អេលីយ៉ាន — ទីប្រឹក្សាជាន់ខ្ពស់ ផ្នែកអនាម័យ និងសំណល់

៤. លោកបណ្ឌិត ចាន់ រ័ត្នបុរី — ទីប្រឹក្សាជាន់ខ្ពស់ ផ្នែកអនាម័យ និងសំណល់

**ពិនិត្យ និងផ្តល់យោបល់ដោយក្រុមការងាររៀបចំនីតិវិធីការគ្រប់គ្រងការងារទឹកកខ្វក់៖**

១. ឯកឧត្តម ប៉េង ពោធិ៍នា — រដ្ឋមន្ត្រី

២. ឯកឧត្តមបណ្ឌិត រស់ វណ្ណា — រដ្ឋលេខាធិការ

៣. ឯកឧត្តម គីម បូរី — អនុរដ្ឋលេខាធិការ

៤. ឯកឧត្តម វង្ស ពិសិដ្ឋ — អនុរដ្ឋលេខាធិការ

៥. ឯកឧត្តម សំរ៉ែងឌី ណាម៉ូ — អនុរដ្ឋលេខាធិការ

# មាតិកា


អារម្ភកថា..................i
បុព្វកថា..................iii
សេចក្តីថ្លែងអំណរគុណ..................iv
បញ្ជីរូបភាព..................ix
បញ្ជីតារាង..................xi
បញ្ជីអក្សរកាត់..................xii
**ជំពូកទី១ សេចក្តីផ្តើម..................១**
១.១ សាវតា..................១
១.២ វិសាលភាព..................១
១.៣ ការថែទាំបណ្តាញលូទឹកកខ្វក់..................២
១.៤ និយមន័យ..................២
១.៥ ប្រភេទនៃការថែទាំ..................៣
១.៦ ភាពចំបាច់ក្នុងការថែទាំ..................៣
១.៧ ទម្រង់នៃគោលការណ៍ណែនាំ..................៣
**ជំពូកទី២ ការត្រួតពិនិត្យ និងការធ្វើតេស្តបណ្តាញលូ..................៥**
២.១ សារសំខាន់នៃការត្រួតពិនិត្យ និងការធ្វើតេស្ត..................៥
២.២ អ្នកត្រួតពិនិត្យ និងធ្វើតេស្ត..................៦
២.៣ គោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យ និងការធ្វើតេស្ត..................៦
២.៤ ការត្រួតពិនិត្យបឋម..................៧
២.៥ ប្រភេទនៃការត្រួតពិនិត្យ និងការធ្វើតេស្ត..................៨
២.៥.១ ការត្រួតពិនិត្យ និងការធ្វើតេស្តដោយផ្ទាល់..................៨
២.៥.២ ការត្រួតពិនិត្យ និងការធ្វើតេស្តដោយប្រយោល..................៩
២.៦ ការត្រួតពិនិត្យ និងការធ្វើតេស្តលូ..................១២
២.៦.១ ការត្រួតពិនិត្យដោយភ្នែកទទេ..................១២
២.៦.២ ការត្រួតពិនិត្យរកការជ្រាបទឹក..................១៧
២.៦.៣ ការត្រួតពិនិត្យអត្រាលំហូរទឹក..................២៣

២.៦.៤ ការត្រួតពិនិត្យការស៊ីរ៉ិចរិល និងភាពចាស់ទ្រុឌទ្រោម..........២៥
២.៦.៥ បម្រុងប្រយ័ត្ន..........២៦
២.៧ បណ្ដាញលូតំណតាមផ្ទះ..........២៧
២.៧.១ ការត្រួតពិនិត្យ និងការធ្វើតេស្ត..........២៧
២.៨ ការត្រួតពិនិត្យ និងការធ្វើតេស្តអណ្ដូងលូ..........២៩
២.៨.១ អណ្ដូងលូ និងឧបករណ៍ផ្សេងទៀត..........២៩
២.៨.២ ការត្រួតពិនិត្យ និងការធ្វើតេស្ត..........២៩
២.៨.៣ អណ្ដូងលូ..........២៩
២.៨.៤ លក្ខខណ្ឌនៅក្នុងអណ្ដូងលូ..........៣០
២.៩ ការវិនិច្ឆ័យលទ្ធផលនៃការត្រួតពិនិត្យ និងការធ្វើតេស្ត..........៣២
២.៩.១ លក្ខណៈវិនិច្ឆ័យសម្រាប់ការឆ្លើយតបបន្ទាន់..........៣២
២.៩.២ ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ ឬការធ្វើតេស្ត..........៣២
២.៩.៣ លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តលូ..........៣៥
២.១០ ការរក្សាកំណត់ត្រា និងសកម្មភាពតាមដាន..........៣៥
២.១០.១ សន្លឹកត្រួតពិនិត្យ..........៣៦
២.១០.២ សៀវភៅបញ្ជី..........៣៦
**ជំពូកទី៣ ការថែទាំបណ្ដាញលូ..........៣៧**
៣.១ ការសម្អាតលូ..........៣៧
៣.១.១ ឧបករណ៍ និងនីតិវិធីសម្អាត..........៣៧
៣.២ ការសម្អាតអណ្ដូងលូ..........៤៤
៣.៣ ការបោះចោលគ្រួស និងសំណល់ភក់..........៤៤
៣.៤ កំណត់ត្រាអំពីការសម្អាតលូ និងការប្រើប្រាស់កំណត់ត្រា..........៤៥
**ជំពូកទី៤ ការការពារ និងការសម្បទាបណ្ដាញលូ..........៤៦**
៤.១ ការការពារបណ្ដាញលូ..........៤៦
៤.២ ការស្ដារសម្បទាលូ..........៤៧
៤.២.១ សេចក្ដីផ្ដើម..........៤៧
៤.២.២ វិធីសាស្ត្រស្ដារសម្បទាលូ..........៤៨

៤.២.៣ ការថែទាំគ្រឿងចក្រ និងឧបករណ៍សម្រាប់ការស្តារសម្បទាលូ..................................៥២
**ជំពូកទី៥ ការអនុវត្តប្រកបដោយសុវត្ថិភាព..........................................................................៥៣**
៥.១ វិធានការសុវត្ថិភាពនៅប្រព័ន្ធលូ........................................................................................៥៣
៥.១.១ គ្រោះថ្នាក់ដោយសារចរាចរណ៍.......................................................................................៥៣
៥.១.២ អណ្តូងលូ.......................................................................................................................៥៤
**ជំពូកទី៦ សេចក្តីសង្ខេប..........................................................................................................៥៧**
ឧបសម្ព័ន្ធ១ ការត្រួតពិនិត្យ និងការធ្វើតេស្តអណ្តូងលូ.......................................................................៥៨
ឧបសម្ព័ន្ធ២ របាយការណ៍ការត្រួតពិនិត្យ.....................................................................................៦០
ឧបសម្ព័ន្ធ៣ ការថែទាំលូ...........................................................................................................៦៥
បញ្ជីឧបករណ៍ដែលរដ្ឋបាលក្រុង ស្រុកត្រូវការសម្រាប់ការប្រតិបត្តការថែទាំបណ្តាញលូ........................៦៧

# បញ្ជីរូបភាព


រូបភាព ១ ទិដ្ឋភាពសំខាន់ៗនៃប្រតិបត្តិការ និងថែទាំងបណ្តាញលូ....................................... ៤
រូបភាព ២ ដំណាក់កាលសំខាន់ៗក្នុងការត្រួតពិនិត្យ និងធ្វើតេស្ត ....................................... ៦
រូបភាព ៣ ការធ្វើតេស្តដោយប្រើកញ្ចក់ឆ្លុះ និងកញ្ចក់ឆ្លុះមានដង....................................... ១១
រូបភាព ៤ ឫសដើមឈើដុះក្នុងលូ ....................................... ១១
រូបភាព ៥ ការខូចខាតរចនាសម្ព័ន្ធលូ និងស្ថានភាពប្រេះតាមបណ្តោយលូ....................................... ១២
រូបភាព ៦ នីតិវិធីនៃការត្រួតពិនិត្យអណ្តូងលូ ....................................... ១៣
រូបភាព ៧ ការត្រួតពិនិត្យដោយប្រើកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍មានដង....................................... ១៤
រូបភាព ៨ ការត្រួតពិនិត្យលូដោយប្រើកាមេរ៉ា CCTV....................................... ១៦
រូបភាព ៩ ដំណើរការសម្រាប់ការត្រួតពិនិត្យលូដោយប្រើកាមេរ៉ា CCTV....................................... ១៦
រូបភាព ១០ សម្ភារៈប្រើប្រាស់សម្រាប់ការងារតេស្តដោយប្រើផ្សែង (A) ម៉ូទ័រផ្លុំផ្សែងនៅអណ្តូងលូ (B) ទៀនផ្សែង (C) សារធាតុរាវបង្កើតផ្សែង....................................... ១៩
រូបភាព ១១ គំនូសព្រាងបង្ហាញអំពីការធ្វើតេស្តដោយប្រើផ្សែង ....................................... ១៩
រូបភាព ១២ នីតិវិធីដំណើរការសម្រាប់ការធ្វើតេស្តដោយប្រើផ្សែង ....................................... ២០
រូបភាព ១៣ ការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង ....................................... ២១
រូបភាព ១៤ នីតិវិធីដំណើរការសម្រាប់ការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង ....................................... ២១
រូបភាព ១៥ រូបអំពីការធ្វើតេស្តដោយការចាក់ទឹកពណ៌....................................... ២៣
រូបភាព ១៦ ដ្យាក្រាមនៃការធ្វើតេស្តដោយការបូម ....................................... ២៤
រូបភាព ១៧ នីតិវិធីការងារនៃការធ្វើតេស្តដោយការបូម....................................... ២៥
រូបភាព ១៨ ប្រព័ន្ធកាមេរ៉ាចល័តប្រើប្រាស់សម្រាប់ប្រភេទលូមុខកាត់តូច (Source: EPA, 2003) និងការធ្វើតេស្តបណ្តាញលូខ្នែងរងដោយប្រើកាមេរ៉ាទូរទស្សន៍ ....................................... ២៨
រូបភាព ១៩ ដំណើរការនៃការត្រួតពិនិត្យបណ្តាញលូខ្នែងរងដោយប្រើកាមេរ៉ាទូរទស្សន៍ ....................................... ២៨
រូបភាព ២០ ឧទាហរណ៍នៃអណ្តូងលូដែលបែកបាក់ (A) គម្របអណ្តូងលូប្រហោង (B) អណ្តូងលូស្ទះ និង (C) កម្ពស់អណ្តូងលូមិនសមស្របទៅនឹងផ្លូវថ្នល់ ....................................... ២៩
រូបភាព ២១ រូបបង្ហាញអំពីលក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តលូ....................................... ៣៤
រូបភាព ២២ ការតំឡើងឧបករណ៍សម្រាប់ការសម្អាតដោយប្រើទឹកតាមវិធីបាល់សម្អាតលូថង់បង្ហូរទឹក (Flush bag)....................................... ៣៨
រូបភាព ២៣ ប្រតិបត្តិការសម្អាតលូដោយប្រើប្រាស់កង់សម្អាតលូ....................................... ៣៩
រូបភាព ២៤ ការដំណើរការដងដោយប្រើថាមពល ....................................... ៤១

រូបភាព ២៥ ក្បាលមានដង ........................................................................................ ៤២
រូបភាព ២៦ វិធីសាស្ត្រការពារសម្រាប់លូចាស់ ............................................................................ ៤៦
រូបភាព ២៧ ដំណើរការបុកទម្លុះលូចាស់ដាក់លូថ្មី........................................................................ ៤៩
រូបភាព ២៨ ដំណើរការដាក់លូរាងគូទខ្យង ............................................................................ ៥០
រូបភាព ២៩ នីតិវិធីតំឡើងការប៉ះលូដោយការដាក់លូថ្មីក្នុងលូចាស់.......................................... ៥០
រូបភាព ៣០ ឧទាហរណ៍នៃអារចំណាំងផ្លាត ............................................................................ ៥៤
រូបភាព ៣១ គម្រូនៃឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួនពេលបំពេញការងារ (A) ឧបករណ៍រកវត្ថុមានឧស្ម័ន (B) ឧបករណ៍បាញ់ខ្យល់ (C) ខ្សែពួរសុវត្ថិភាព និង (D) មួកសុវត្ថិភាព...................................................................... ៥៤
រូបភាព ៣២ គម្រូឧបករណ៍ដកដង្ហើមគេចចេញបន្ទាន់ ............................................................ ៥៦
រូបភាព ៣៣ វដ្តនៃការប្រតិបត្តិ និងថែទាំប្រព័ន្ធលូទឹកកខ្វក់..................................................... ៥៧

# បញ្ជីតារាង


តារាង ១ ការត្រួតពិនិត្យបឋមនៅក្នុងរយៈពេលនៃការទទួលខុសត្រូវ (DLP)........................ ៧
តារាង ២ ការត្រួតពិនិត្យបឋមសម្រាប់អណ្តូងលូ និងលូ.................................................. ៨
តារាង ៣ រយៈពេលត្រួតពិនិត្យបឋមសម្រាប់បណ្តាញលូដាច់ដោយឡែក និងអណ្តូងលូ......... ៨
តារាង ៤ វិធីសាស្ត្រការត្រួតពិនិត្យ និងការធ្វើតេស្តលូដោយប្រយោល ................................ ៩
តារាង ៥ បច្ចេកវិទ្យាត្រួតពិនិត្យបណ្តាញលូអាចអនុវត្តបានចំពោះលក្ខខណ្ឌប្រទេសកម្ពុជា ..១០
តារាង ៦ គុណសម្បត្តិ និងគុណវិបត្តិរវាងវិធីសាស្ត្រត្រួតពិនិត្យដោយភ្នែកទទេ និងដោយប្រើប្រាស់កាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍ ................................................១៤
តារាង ៧ ឧស្ម័នដែលត្រូវវាស់វែងដោយឧបករណ៍កំណត់វត្តមានឧស្ម័ន (អាចខុសគ្នាពីឧបករណ៍មួយទៅមួយ)...................................................................................................២៦
តារាង ៨ ចំណុចផ្សេងៗដែលត្រូវត្រួតពិនិត្យ និងធ្វើតេស្ត ............................................ ៣០
តារាង ៩ លក្ខណៈវិនិច្ឆ័យសម្រាប់ការធ្វើតេស្តគម្លាតរួមនៃលូ.......................................... ៣២
តារាង ១០ លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តសម្រាប់បំពង់លូនីមួយៗ ....................................៣៣
តារាង ១១ លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តលូ ............................................................... ៣៥
តារាង ១២ និយមន័យពាក្យគន្លឹះ..........................................................................................៤៨

# បញ្ជីអក្សរកាត់

| | |
|---|---|
| CCTV | (Closed-circuit Television) ការត្រួតពិនិត្យដោយប្រើកាមេរ៉ាតាមដាន |
| CIPP | (Cured-In-Place Pipe) ការប៉ះលូដោយដាក់លូថ្មីក្នុងលូចាស់ |
| DLP | (Defect Liability Period) រយៈពេលនៃការទទួលខុសត្រូវ |
| GDSWM | (General Directorate of Sewerage and Wastewater Management) អគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ |
| GGGI | (Global Green Growth Institute) វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល |
| GIZ | (Gesellschaft für Internationale Zusammenarbeit) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| GRP | (Glass fiber Reinforced Plastic) ទុយោ GRP |
| HDPE | (High-Density Polyethylene) ប៉ូលីអេទីឡែនដង់ស៊ីតេខ្ពស់ |
| MPWT | (Ministry of Public Works and Transport) ក្រសួងសាធារណការ និងដឹកជញ្ជូន |
| O&M | (Operation and Maintenance) ប្រតិបត្តិការ និងថែទាំ |
| PCCP | (Prestressed Concrete Cylinder Pipe) លូមូលបេតុង |
| SASW | (Spectral Analysis of Surface Waves) ការវិភាគវិសាលគមន៍រលកផ្ទៃខាងលើ |
| STP | (Sewage Treatment Plant) ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ |
| uPVC | (Unplasticised Polyvinyl Chloride) បំពង់ទីបជ័រ uPVC |
| WC | (Water Closet) បង្គន់ |

# ជំពូកទី ១
# សេចក្ដីផ្ដើម

## ១.១ សាវតា

គោលការណ៍ណែនាំស្ដីពីប្រតិបត្តិការ និងថែទាំបណ្ដាញលូទឹកកខ្វក់គឺជាការកែសម្រួល និងធ្វើបច្ចុប្បន្នភាពពីគោលការណ៍ណែនាំស្ដីពីប្រតិបត្តិការ និងថែទាំប្រព័ន្ធទឹកកខ្វក់ដែលបានបោះពុម្ពផ្សាយដោយក្រសួងសាធារណការ និងដឹកជញ្ជូន រួមជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (Global Green Growth Institute) ក្នុងឆ្នាំ២០១៨។

ចំណុចខុសគ្នាចំបងនៃគោលការណ៍ណែនាំថ្មីនេះគឺផ្ដោតតែទៅលើប្រតិបត្តិការ និងថែទាំបណ្ដាញលូទឹកកខ្វក់ដែលរួមមាន បណ្ដាញលូរួម និងបណ្ដាញលូដាច់ដោយឡែកតែប៉ុណ្ណោះ។ គោលការណ៍ណែនាំថ្មីនេះ បានរក្សាទុកជំពូកដែលពាក់ពន្ធ័នឹងគោលការណ៍ណែនាំចាស់ស្ទើរតែទាំងស្រុង និងបានបន្ថែមជំពូកសំខាន់ៗមួយចំនួនទៀត ទៅតាមការផ្ដល់យោបល់ត្រឡប់ពីភាគីពាក់ព័ន្ធនានា។ គោលការណ៍ណែនាំថ្មីនេះ មានគោលបំណងផ្ដល់នូវការណែនាំដល់ រដ្ឋបាលក្រុងស្រុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបន្ទុកថែទាំបណ្ដាញលូទឹកកខ្វក់នាពេលបច្ចុប្បន្ន ឬនាពេលអនាគត។ គោលការណ៍ណែនាំនេះក៏មានគោលបំណងផ្ដល់នូវការគាំទ្រដល់រដ្ឋបាលក្រុងស្រុក ក្នុងការពង្រឹង ធ្វើឱ្យប្រសើរឡើង និងធានាបាននូវដំណើរការប្រតិបត្តិការ និងថែទាំបណ្ដាញលូទឹកកខ្វក់នៅក្នុងប្រទេស។

ការកែសម្រួល និងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំនេះគ្រោងនឹងធ្វើឡើងរៀងរាល់ ៤ ឆ្នាំម្ដង ដោយផ្អែកលើយោបល់ត្រឡប់ពីភាគីពាក់ព័ន្ធ និងអ្នកអនុវត្តផ្ទាល់។ ការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំនេះក៏នឹងអាស្រ័យលើការផ្លាស់ប្ដូរបច្ចេកវិទ្យាប្រព័ន្ធអនាម័យ នៅក្នុងប្រទេសផងដែរ។

## ១.២ វិសាលភាព

គោលការណ៍ណែនាំថ្មីនេះគ្របដណ្ដប់ដំណើរការដែលទាក់ទងនឹងប្រតិបត្តិការ និងថែទាំដោយរាប់បញ្ចូលទាំងបណ្ដាញលូរួម និងបណ្ដាញលូដាច់ដោយឡែក និងផ្ដល់នូវនីតិវិធីលម្អិតក្នុងការថែទាំប្រព័ន្ធលូ រាប់បញ្ចូលទាំងបណ្ដាញលូទឹកកខ្វក់ (បណ្ដាញលូរួម និងបណ្ដាញលូដាច់ដោយឡែក) បណ្ដាញលូមេ បណ្ដាញលូមេរង និងបណ្ដាញលូខ្នែង អណ្ដូងលូ និងការត្រួតពិនិត្យផ្សេងៗទៀតដែលពាក់ពន្ធ័នឹងបណ្ដាញលូ។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងដោយយោងតាមបច្ចេកវិទ្យាអនាម័យដែលកំពុងប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១.៣ ការថែទាំបណ្តាញលូទឹកកខ្វក់

បណ្តាញលូ គឺរួមបញ្ចូលជាមួយហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់រាវ។ បណ្តាញលូត្រូវបានប្រើប្រាស់ដើម្បីប្រមូល និងបញ្ជូនសំណល់រាវទៅក្នុងស្ថានីយប្រព្រឹត្តិកម្មសំណល់រាវមុននឹងបញ្ចេញចោល។ ប្រព័ន្ធលូរួមមាន បណ្តាញលូ ប្រព័ន្ធលូ ស្ថានីយបូម បណ្តាញលូមេ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដែលប្រើប្រាស់ដើម្បីប្រមូលសំណល់រាវពីតាមផ្ទះ រោងចក្រ និងតំបន់អាជីវកម្មផ្សេងៗ ដើម្បីបញ្ជូនទៅស្ថានីយប្រព្រឹត្តិកម្ម។ នៅពេលដែលតំឡើងបណ្តាញលូរួចរាល់ ការថែទាំបណ្តាញលូទាំងនោះឱ្យបានត្រឹមត្រូវមានសារសំខាន់ណាស់ ដើម្បីធានាបាននូវប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងសំណល់រាវ។

គុណភាពនៃការថែទាំបណ្តាញលូរួមមាន ការប្រើប្រាស់កម្លាំងពលកម្ម ឧបករណ៍ និងសម្ភារៈដើម្បីរក្សាបណ្តាញលូឱ្យល្អ និងអាចប្រមូល និងបញ្ជូនទឹកកខ្វក់ទៅស្ថានីយប្រព្រឹត្តិកម្ម។

## ១.៤ និយមន័យ

ដើម្បីធានានូវសង្គតិភាពជាមួយនឹងនិយមន័យដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២៣៥ និយមន័យនៃពាក្យគន្លឹះសំខាន់ៗមួយចំនួនត្រូវបានដកស្រង់ចេញពីអនុក្រឹត្យលេខ ២៣៥ ស្តីពី "ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់" ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។

- ***ទឹកកខ្វក់៖*** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួច មានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យ រួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ ទីរមណីយដ្ឋាន ឬមណ្ឌលកម្សាន្ត។
- ***សំណល់រាវ៖*** សំដៅដល់ទឹកសំណល់ដែលមានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការដោយផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។
- ***ប្រព័ន្ធ/បណ្តាញលូទឹក៖*** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់ រួមមាន៖ តំណភ្ជាប់អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។
- ***បណ្តាញរួម៖*** សំដៅដល់ប្រព័ន្ធលូប្រមូល និងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងជាមួយគ្នា។
- ***បណ្តាញលូដាច់ដោយឡែក៖*** សំដៅដល់ប្រព័ន្ធលូប្រមូល និងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងញែកដាច់ផ្សេងពីគ្នា។
- ***បណ្តាញលូមេ៖*** សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងអាងស្តុកទឹក ស្ថានីយបូម ឬស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់។
- ***បណ្តាញលូមេរង៖*** សំដៅដល់ប្រព័ន្ធលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ និងទទួលទឹកកខ្វក់ពីបណ្តាញលូខ្នែង។

- ***បណ្តាញលូខ្មែង៖*** សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ ឬបណ្តាញលូមេរង។
- ***បណ្តាញលូខ្មែងរង៖*** សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូខ្មែង និងទទួលទឹកកខ្វក់ពីទីតាំង ឬប្រភពបញ្ចេញ។
- ***អាងសិបទិច៖*** សំដៅដល់អាងទទួលទឹកកខ្វក់ដែលប្រើប្រាស់ដើម្បីប្រមូលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក បន្ទាប់មកធ្វើការបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ តាមរយៈសកម្មភាពបាក់តេរីមុននឹងបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈ។
- ***សំណល់ភក់៖*** សំដៅដល់ភក់ ឬកាកសំណល់ពីអាងសិបទិច ឬប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់។
- ***ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់៖*** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមទឹក ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង និងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់។
- ***ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់រួម៖*** សំដៅដល់រោងចក្រប្រព្រឹត្តិកម្មទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

## ១.៥ ប្រភេទនៃការថែទាំ

ការថែទាំបណ្តាញលូមានចំនួនបីប្រភេទ គឺការថែទាំបង្ការ ការថែទាំជាប្រចាំ និងការថែទាំបន្ទាន់។ ការថែទាំបង្ការ ឬការថែទាំជាប្រចាំគួរធ្វើឡើងដើម្បីបង្ការការបែកបាក់ និងបញ្ចៀសនូវប្រតិបត្តិការបន្ទាន់ដើម្បីដោះស្រាយបញ្ហាស្ទះបណ្តាញលូ ឬទឹកហៀរចេញពីអណ្តូងលូ ឬការហៀរទឹកកខ្វក់ចូលក្នុងផ្ទះ ឬការខូចហេដ្ឋារចនាសម្ព័ន្ធរបស់បណ្តាញ។ ការថែទាំបង្ការចំណាយថវិកាតិច និងផ្តល់នូវទំនុកចិត្តក្នុងប្រតិបត្តិការបណ្តាញលូ។ ប្រសិនបើការថែទាំបានត្រឹមត្រូវ ការជួសជុលបន្ទាន់នឹងកម្រកើតមានផងដែរ។ ការត្រួតពិនិត្យបានត្រឹមត្រូវ និងការថែទាំបង្ការពិតជាចាំបាច់។

## ១.៦ ភាពចំបាច់ក្នុងការថែទាំ

ការថែទាំជួយការពារការចំណាយមូលធន និងធានាឱ្យមានប្រសិទ្ធភាព និងការសន្សំសំចៃលើការចំណាយប្រតិបត្តិការ និងការថែទាំបណ្តាញលូ។ ការថែទាំក៏ជួយកសាង និងរក្សាទំនាក់ទំនងល្អជាមួយសាធារណជនដែលយល់ដឹង និងគាំទ្រការថែទាំបណ្តាញលូ គឺមានសារសំខាន់ណាស់ដើម្បីធានាឱ្យបាននូវភាពជោគជ័យនៃបណ្តាញលូដែលកំពុងប្រើប្រាស់។ រដ្ឋបាលក្រុង ស្រុកត្រូវធានាថាបណ្តាញលូមានសារសំខាន់នៅក្នុងការលើកកម្ពស់អនាម័យនៅក្នុងប្រទេស។

## ១.៧ ទម្រង់នៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះបែងចែកជាបួនផ្នែកដែលផ្នែកនីមួយៗគ្របដណ្តប់ទិដ្ឋភាពសំខាន់ៗនៃប្រតិបត្តិការ និងថែទាំបណ្តាញលូទឹកកខ្វក់ ដូចបង្ហាញនៅក្នុងរូបភាព ១។

ក. ផ្នែកទី ១ (ជំពូកទី ២) ផ្តល់នូវសេចក្តីលម្អិតអំពីដំណើរការក្នុងការត្រួតពិនិត្យ និងការធ្វើតេស្តប្រព័ន្ធលូដែលត្រូវការជាប្រចាំ ដើម្បីទទួលបាននូវបណ្តាញលូដែលដំណើរការល្អ និងកំណត់ពីតម្រូវការថែទាំ ឬជួសជុល។

ខ. ផ្នែកទី ២ (ជំពូកទី ៣) រៀបរាប់ពីនីតិវិធីថែទាំជាប្រចាំ និងបញ្ជីត្រួតពិនិត្យដែលត្រូវប្រើប្រាស់សម្រាប់ប្រព័ន្ធទឹកកខ្វក់។

គ. ផ្នែកទី ៣ (ជំពូកទី ៤) រៀបរាប់ពីបញ្ហាដែលកើតឡើងញឹកញាប់ក្នុងកំឡុងពេលប្រតិបត្តិការ និងការថែទាំបណ្តាញលូទឹកកខ្វក់ និងវិធីសាស្ត្រការពារ និងការស្តារសម្បទាលូ។

ឃ. ផ្នែកទី ៤ (ជំពូកទី ៥) បរិយាយពីទិដ្ឋភាពសំខាន់ៗនៃសុវត្ថិភាព ដែលផ្តោតទៅលើហានិភ័យពីចរាចរតាមដងផ្លូវ និងកិច្ចការនៅក្នុងអណ្តូងលូ។




*រូបភាព ១. ទិដ្ឋភាពសំខាន់ៗនៃប្រតិបត្តិការ និងថែទាំបណ្តាញលូ*

# ជំពូកទី ២
# ការត្រួតពិនិត្យ និងការធ្វើតេស្តបណ្តាញលូ

## ២.១ សារសំខាន់នៃការត្រួតពិនិត្យ និងការធ្វើតេស្ត

បណ្តាញលូ គឺជាវិធីសាស្ត្រដែលអាចទុកចិត្តបានក្នុងការបញ្ជូនទឹកកខ្វក់ពីប្រភពបញ្ចេញនីមួយៗទៅក្នុងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់។ ការត្រួតពិនិត្យ និងការធ្វើតេស្តគឺជាបច្ចេកទេសដែលប្រើប្រាស់ ដើម្បីប្រមូលព័ត៌មានសម្រាប់បង្កើតកម្មវិធីប្រតិបត្តិការ និងថែទាំ ដើម្បីធានាថា ទាំងប្រព័ន្ធប្រមូលទឹកកខ្វក់ថ្មី និងមានស្រាប់ដំណើរការស្របទៅតាមគោលបំណងដែលបានកំណត់។ ការត្រួតពិនិត្យ និងការធ្វើតេស្តមានភាពចាំបាច់នៅក្នុង៖

- ការកំណត់បញ្ហាដែលកំពុងកើតឡើង ឬដែលអាចនឹងកើតឡើងនៅក្នុងប្រព័ន្ធប្រមូលទឹកកខ្វក់
- ការវាយតម្លៃភាពធ្ងន់ធ្ងរនៃបញ្ហាដែលបានរកឃើញ
- ការស្វែងរកចំណុចមានបញ្ហា និង
- ការផ្តល់របាយការណ៍ច្បាស់លាស់ ត្រឹមត្រូវ និងមានអត្ថន័យគ្រប់គ្រាន់ដល់ថ្នាក់លើពាក់ព័ន្ធនឹងបញ្ហាដែលកំពុងកើតឡើង ឬអាចនឹងកើតឡើង។

គោលបំណងចម្បងពីរនៃការត្រួតពិនិត្យ និងការធ្វើតេស្ត គឺដើម្បីបង្ការការលេចធ្លាយបណ្តាញលូដែលអាចកើតឡើង និងស្វែងរកកន្លែងលេចធ្លាយចាស់ៗដើម្បីជួសជុល។

កំហុសរបស់អ្នកគូរប្លង់ និងការធ្វេសប្រហែសក្នុងការសាងសង់ គឺជាប្រភពបញ្ហាដោយផ្ទាល់នៃការខូចប្រព័ន្ធលូ។ ដោយសារប្រព័ន្ធលូមានអាយុកាលចាស់ និងសម្ភារលូកាន់តែទ្រុឌទ្រោមបង្កឡើងដោយប្រតិកម្មរបស់អ៊ីដ្រូសែនស៊ុលហ្វីត ឬសារធាតុគីមីផ្សេងៗទៀត ការស្រុតគ្រឹះលូ និងការលេចធ្លាយតាមមុខតំណអាចបណ្តាលឱ្យខូចរចនាសម្ព័ន្ធប្រព័ន្ធលូ។ ចាប់តាំងពីការខូចដំបូងរហូតដល់ការបាក់ស្រុតប្រព័ន្ធលូមានរយៈពេលយូរណាស់។ ការប្រេះ ឬលេចធ្លាយតំណនឹងធ្វើឱ្យទឹកក្រោមដី ព្រមទាំងល្បាយដីហូរចូលទៅក្នុងប្រព័ន្ធលូ បង្កឱ្យមានស្នាមប្រហោងនៅកន្លែងនោះ ដែលធ្វើឱ្យគ្រឹះលូស្រុតចុះបន្តិចម្តងៗ ហើយចុងក្រោយគឺប្រព័ន្ធលូបាក់ស្រុតតែម្តង។

ជាញឹកញាប់ ដីបៀមទឹកហូរចេញពីបាតក្រោមតាមបណ្តោយបណ្តាញលូ។ ប្រភេទនៃការខូចខាតទាំងនេះគឺជាតម្រុយនៃមូលហេតុដែលបង្កឱ្យខូចប្រព័ន្ធលូ។ ស្នាមដាច់ប្រេះដោយសារការខូចគ្រឹះ និងចលនាផែនដីបណ្តាលឱ្យលូបាក់ជាកំណាត់ៗ។ ការផ្ទុកលើសចំណុះ ទាំងខាងក្នុង និងខាងក្រៅបណ្តាលឱ្យបែកតាមបណ្តោយលូ។ ការបែកបាក់បង្កឡើងដោយសម្ពាធពីខាងក្នុង បណ្តាលឱ្យលូប្រេះ ឯការផ្ទុកលើសទម្ងន់ពីខាងក្រៅបណ្តាលឱ្យបែកលូផ្នែកខាងលើ។ ការត្រួតពិនិត្យប្រព័ន្ធលូជាប្រចាំ កំណត់ពីលូដែលត្រូវការថែទាំមុននឹងឈានដល់ការខូច និងបែកបាក់ទាំងស្រុង។ ដើម្បី

ការពារប្រព័ន្ធលូកុំឱ្យខូចខាតធ្ងន់ធ្ងរដូចរៀបរាប់ខាងលើ វិស្វករថែទាំគួរតែរៀបចំកម្មវិធីត្រួតពិនិត្យ និងធ្វើតេស្តឱ្យបានគ្រប់គ្រាន់។

## ២.២ អ្នកត្រួតពិនិត្យ និងធ្វើតេស្ត

យោងតាមអនុក្រឹត្យលេខ ២៣៥ របស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋបាលក្រុងស្រុកជាអ្នកទទួលបន្ទុកក្នុងប្រតិបត្តិការ និងថែទាំប្រព័ន្ធគ្រប់គ្រងសំណល់រាវ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលក្រុង ស្រុក ជាអ្នកទទួលខុសត្រូវរួមក្នុងការថែទាំ ការត្រួតពិនិត្យ និងការធ្វើតេស្តបណ្តាញលូ អណ្តូងលូ និងសេវាកម្មនៃការតភ្ជាប់បណ្តាញលូនៅតាមផ្ទះ។

ទោះបីជាជួលក្រុមហ៊ុនឯកជនដើម្បីផ្តល់សេវាកម្មថែទាំបណ្តាញលូក៏ដោយ ក៏ការទទួលខុសត្រូវចុងក្រោយដើម្បីធានានូវការថែទាំបានគ្រប់គ្រាន់ នៅតែជាបន្ទុករបស់រដ្ឋបាលក្រុង ស្រុក។ ដូចនេះ រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់គោលការណ៍ណែនាំនេះជាមូលដ្ឋានសម្រាប់បែងចែកតួនាទី និងការទទួលខុសត្រូវនៅក្នុងរចនាសម្ព័ន្ធក្រុមការងាររបស់ខ្លួន។ រដ្ឋបាលក្រុង ស្រុក ត្រូវពិនិត្យមើលរបាយការណ៍/បញ្ជីត្រួតពិនិត្យឡើងវិញមុននឹងអនុម័តកិច្ចការថែទាំបណ្តាញលូ។

## ២.៣ គោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យ និងការធ្វើតេស្ត

ឯកសារ និងទិន្នន័យដែលផ្តល់ព័ត៌មានអំពីស្ថានភាពប្រព័ន្ធលូ មានភាពចាំបាច់ណាស់សម្រាប់ប្រតិបត្តិការ និងថែទាំប្រព័ន្ធលូ។ ការត្រួតពិនិត្យ និងធ្វើតេស្តប្រព័ន្ធលូដែលមានវិសាលភាពលើតំបន់ធំទូលាយក៏ត្រូវការជាចាំបាច់នូវពេលវេលា និងចំណាយថវិកាច្រើនផងដែរ។

ត្រូវធ្វើការត្រួតពិនិត្យបឋមដើម្បីភាពងាយស្រួលក្នុងការទទួលបានឯកសារ និងទិន្នន័យដែលអាច យកមកប្រើប្រាស់ ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសប្រព័ន្ធលូណាដែលត្រូវធ្វើការត្រួតពិនិត្យ/ធ្វើតេស្ត ព្រមទាំងកំណត់អាទិភាពតាមទីតាំងទាំងនោះ បន្ទាប់មកសម្រេចចិត្តជ្រើសរើសប្រព័ន្ធលូដែលនឹងត្រូវត្រួតពិនិត្យ/ធ្វើតេស្តចុងក្រោយ ដើម្បីទទួលបានទិន្នន័យប្រកបដោយប្រសិទ្ធភាព។ ជាដំបូង វិធីសាស្ត្រនេះត្រូវមានព័ត៌មានមូលដ្ឋានជាមុនសិន តាមរយៈការត្រួតពិនិត្យបឋម ដើម្បីធ្វើតេស្ត និងត្រួតពិនិត្យប្រវែងប្រព័ន្ធលូ ឬតំបន់លូជាក់លាក់ដូចក្នុងរូបភាព ២។




*រូបភាព ២. ដំណាក់កាលសំខាន់ៗក្នុងការត្រួតពិនិត្យ និងធ្វើតេស្ត*

## ២.៤ ការត្រួតពិនិត្យបឋម

នៅពេលធ្វើការត្រួតពិនិត្យបឋមទៅលើប្រព័ន្ធលូ គួរតែបញ្ជាក់អំពីការស្រុត ការបាក់ ឬការហៀរទឹកចេញទៅលើផ្លូវដែលដាក់លូ។ ការខូចទ្រង់ទ្រាយ ឬការខូចប្រព័ន្ធលូ និងសំណល់ខ្សាច់ និងភក់ក៏ត្រូវបញ្ជាក់ផងដែរនៅពេលធ្វើការអង្កេតអណ្តូងលូ។ ប្រសិនបើមានការបញ្ជាក់អំពីការខូចខាត ឬករណីដែលអាចធ្វើមានការខូចខាតទៅលើប្រព័ន្ធលូ ឬប្រសិនបើមានភាពខុសប្រក្រតីណាមួយនៅពេលធ្វើការត្រួតពិនិត្យបឋមនោះ អ្នកគ្រប់គ្រងប្រព័ន្ធលូ គួរតែធ្វើតេស្តនិងត្រួតពិនិត្យទីតាំងពាក់ព័ន្ធដូចខាងក្រោម៖

- ការស៊ីរិចរិល ភាពសឹករិចរិល ការខូច ឬការប្រេះប្រព័ន្ធលូ
- ការជ្រាបទឹក
- ការស៊ីរិចរិលជើងលូ សឹកគម្របលូ អណ្តូងលូខូចទ្រង់ទ្រាយ អណ្តូងលូកប់ក្នុងដី
- ក្លិនខុសពីធម្មតា
- ការស្ទះ និងការហៀរទឹកចេញ

រយៈពេលស្នើសុំធ្វើការត្រួតពិនិត្យបឋម គឺអាស្រ័យលើការវាយតម្លៃប្រកបដោយវិជ្ជាជីវៈទៅតាមលក្ខខណ្ឌក្នុងគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការ និងថែទាំ ក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តដូចក្នុងតារាង ១ តារាង ២ និងតារាង ៣។

*តារាង ១. ការត្រួតពិនិត្យបឋមនៅក្នុងរយៈពេលនៃការទទួលខុសត្រូវ (DLP)*

| ប្រភេទ / ដំណាក់កាលត្រួតពិនិត្យ | អណ្តូងលូ | លូ | ស៊ីហ្វុងផ្កាប់ | ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតនៃប្រព័ន្ធលូ |
|---|---|---|---|---|
| ការត្រួតពិនិត្យបឋម/ដំបូង | ក្នុងរយៈពេល ៣ខែដំបូងបន្ទាប់ពីចាប់ផ្តើម DLP (ដើម្បីបង្ហាញអំពីចំណុចខ្វះខាតនៃគុណភាពសំណង់ដែលមើលមិនឃើញណាមួយ) | | | |
| ការត្រួតពិនិត្យចុងក្រោយ | ក្នុងរយៈពេល ៣ ខែចុងក្រោយនៃ DLP | | | |
| ការត្រួតពិនិត្យបន្ថែម ប្រសិនបើ DLP លើសពី ៤ ឆ្នាំ | ធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តងក្រោយពេលធ្វើការត្រួតពិនិត្យដំបូងក្នុង DLP | | | |

*តារាង ២. ការត្រួតពិនិត្យបឋមសម្រាប់អណ្តូងលូ និងលូ*

| ប្រភេទ / លក្ខខណ្ឌផ្លូវ និងចរាចរណ៍ | អណ្តូងលូ | លូ |
|---|---|---|
| ផ្លូវមានចរាចរណ៍ច្រើន និងចម្រុះ | មួយឆ្នាំម្តង | ២ ឆ្នាំម្តង |
| ផ្លូវទទឹងចាប់ពី២ម៉ែត្រ ទៅ៥ម៉ែត្រ និងមានចរាចរណ៍ចម្រុះ | ២ ឆ្នាំម្តង | ២ ឆ្នាំម្តង |
| ផ្លូវ និងគន្លងផ្លូវទទឹងតិចជាង ២ ម៉ែត្រ | ៣ ឆ្នាំម្តង | ៣ ឆ្នាំម្តង |
| ចិញ្ចើមផ្លូវលើកខ្ពស់ខណ្ឌសម្រាប់ថ្មើរជើង (ជាទូទៅតាមផ្លូវធំ) | ២ ឆ្នាំម្តង | ៣ ឆ្នាំម្តង |
| ផ្នែកផ្សេងៗទៀត (ដូចជា តំណភ្ជាប់តាមផ្ទះ ស៊ីហ្វុងផ្កាប់ និងលូមេ) នៃបណ្តាញលូ | ១ ឆ្នាំម្តង | |

*តារាង ៣. រយៈពេលត្រួតពិនិត្យបឋមសម្រាប់បណ្តាញលូដាច់ដោយឡែក និងអណ្តូងលូ*

| ល.រ | ឈ្មោះនៃផ្នែកផ្សេងៗដែលត្រូវត្រួតពិនិត្យ | ភាពញឹកញាប់នៃការត្រួតពិនិត្យ |
|---|---|---|
| ១. | លូ និងអណ្តូងលូ | |
| | មុខកាត់ ៣០០–៦០០មីលីម៉ែត្រ | ៦ ខែម្តង |
| | មុខកាត់ >៦០០–១០០០ មីលីម៉ែត្រ | ១ ឆ្នាំម្តង |
| | មុខកាត់ > ១០០០ មីលីម៉ែត្រ | ២ ឆ្នាំម្តង |
| ២. | ទរទឹកតាមផ្លូវ និងច្រកទឹកចូល | ៦ ខែម្តង (មុនរដូវវស្សា) |
| ៣. | សំណង់លូត្រង់ច្រកទឹកចេញ | ៦ ខែម្តង (មុនរដូវវស្សា) |

## ២.៥ ប្រភេទនៃការត្រួតពិនិត្យ និងការធ្វើតេស្ត

ដើម្បីវាយតម្លៃស្ថានភាពលូ ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យ និងការធ្វើតេស្ត។ ជាទូទៅ ការត្រួតពិនិត្យ និងការធ្វើតេស្តមានពីរប្រភេទ៖

- វិធីសាស្ត្រផ្ទាល់
- វិធីសាស្ត្រប្រយោល

### *២.៥.១ ការត្រួតពិនិត្យ និងការធ្វើតេស្តដោយផ្ទាល់*

ការត្រួតពិនិត្យ និងការធ្វើតេស្តដោយផ្ទាល់ធ្វើឡើងដោយឱ្យមនុស្សម្នាក់ចុះទៅក្នុងលូ មុនពេលដាក់អោយដំណើការប្រព័ន្ធលូ ដើម្បីត្រួតពិនិត្យស្ថានភាពលូដោយផ្ទាល់ភ្នែក។ ការត្រួតពិនិត្យនេះ មិនត្រូវធ្វើឡើងនៅពេលប្រព័ន្ធលូត្រូវបានដាក់ឱ្យប្រើប្រាស់ឡើយ សូម្បីតែលូថ្មីក៏ដោយ ក៏ត្រូវតែមានអង្កត់ផ្ចិតខាងក្នុងធំជាង ២ ម៉ែត្រ ។ ត្រូវតែមានការប្រុងប្រយ័ត្នទុកជាមុនអំពីសុវត្ថិភាពចាំបាច់សម្រាប់ការងារនៅកន្លែងបិទជិត ដោយហាមដាច់ខាតការប្រើញញួរ ឬឧបករណ៍ផ្សេងទៀតវាយជញ្ជាំងលូ។ គោលបំណងតែមួយគត់នៃការធ្វើបែបនេះ គឺដើម្បីមើលឃើញជាក់ស្តែងថាតំណ

លូបានភ្ជាប់ត្រឹមត្រូវ។ នៅពេលលូត្រូវបានដាក់ឱ្យប្រើប្រាស់ ការអនុវត្តបែបនេះត្រូវបានហាមឃាត់ជារៀងរហូត។

### ២.៥.២ ការត្រួតពិនិត្យ និងការធ្វើតេស្តដោយប្រយោល

វិធីសាស្ត្រនេះប្រើប្រាស់បច្ចេកវិទ្យាជាជំនួយដល់ការត្រួតពិនិត្យជំនួសឱ្យមនុស្សដើរចូលក្នុងលូ។ បច្ចេកវិទ្យាសម្រាប់ការត្រួតពិនិត្យ និងការធ្វើតេស្តដោយប្រយោលនេះមានក្នុងតារាង ៤។

ទោះបីមាន បច្ចេកវិទ្យាច្រើនយ៉ាងណាក៏ដោយក៏ បច្ចេកវិទ្យាដែលត្រូវជ្រើសរើសនៅតែអាស្រ័យ ទៅលើលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុករបស់អ្នកប្រើប្រាស់។ ការចងក្រងបច្ចេកវិទ្យាសាមញ្ញ និងអាចអនុវត្តបានមានបង្ហាញនៅក្នុងតារាង ៥។ ការប្រើប្រាស់ពន្លឺភ្លើង និងកញ្ចក់ឆ្លុះគឺជាបច្ចេកវិទ្យាចាស់បំផុតដែលគេធ្លាប់ស្គាល់ ដូចបង្ហាញក្នុងរូបភាព ៣។ អណ្តូងលូពីរជាប់គ្នាត្រូវតែបើកចំហ និងទុកឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់ រយៈពេលប្រហែលមួយម៉ោង។ បន្ទាប់មក ដាក់កញ្ចក់ឆ្លុះមានដងវែងដែលកាច់ក្នុងកម្រិតមុំ ៤៥ដឺក្រេធៀបនឹងដងត្រូវបន្ទាបចូលទៅក្នុងបាតអណ្តូងលូ ហើយចាំងពន្លឺភ្លើងដាក់កញ្ចក់ពីខាងលើ ដើម្បីឱ្យបាច់ពន្លឺចាំងផ្លាតនៅមុំ ៩០ដឺក្រេតាមទិសដេកទៅក្នុងលូ ហើយមើលឃើញពន្លឺភ្លើងនៅអណ្តូងលូម្ខាងទៀត។ ការងារនេះនឹងកាន់តែងាយស្រួលធ្វើនៅពេលព្រលប់ៗ។ ការធ្វើបែបនេះ អាចប្រាប់បានថាតើរន្ធលូមានស្ទះ ឬស្អាត ឬការតម្រៀបលូបានត្រង់ ឬទេ។

កាមេរ៉ាតាមដាន ត្រូវបានរុញតាមបណ្តោយលូដោយឧបករណ៍បញ្ជា ហើយប្រើភ្លើងតពីរថយន្តវ៉ែន បន្ទាប់មកកាមេរ៉ានេះក៏ចូលតាមបណ្តោយលូ រួចបញ្ជូនរូបភាពក្នុងកាមេរ៉ាទៅកាន់ទូរទស្សន៍នៅក្នុងរថយន្តវ៉ែនវិញ។ ប្រព័ន្ធសូណាក៏មានលក្ខណៈស្រដៀងគ្នាដែរ។ ឧបករណ៍រ៉ូបូតមួយត្រូវបានបញ្ជូនតាមបណ្តោយលូ ហើយវាបញ្ចេញរលកសំឡេងដែលមានប្រេកង់ខ្ពស់ទៅប៉ះនឹងផ្ទៃលូ រួចត្រលប់ទៅកាន់ឧបករណ៍បញ្ជូនវិញដោយសារចំណាំងផ្លាតរលកសំឡេង។ ការដឹងពីវត្ថុធាតុដើមសំណង់ជញ្ជាំងលូក៏អាចចងក្រងជាកម្មវិធី ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពរចនាសម្ព័ន្ធនៃជញ្ជាំងលូបានដែរ។

***តារាង ៤. វិធីសាស្ត្រការត្រួតពិនិត្យ និងការធ្វើតេស្តលូដោយប្រយោល***

| បច្ចេកវិទ្យា | | ប្រភេទលូ | | | វត្ថុធាតុដើមលូ | អង្កត់ផ្ចិតលូ (មីលីម៉ែត្រ) | ចំណុចខ្វះខាតគុណភាព | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ទំនាញផែនដី | លូមេ | ខ្វែងរង | | | ប្រព័ន្ធលូខាងក្នុង | ជញ្ជាំងលូ | ការលេចជ្រាប | ទម្រង់លូ |
| កាមេរ៉ា | កាមេរ៉ាឌីជីថល | ✔ | | | អ្វីក៏បាន | ១៥០ -១៥០ | ✔ | ✔ | ✔ | |
| | កាមេរ៉ាពង្រីក | ✔ | | | អ្វីក៏បាន | > ១៥០ | ✔ | ✔ | ✔ | |
| | កាមេរ៉ារុញ | | | ✔ | អ្វីក៏បាន | ≤ ៣០០ | ✔ | ✔ | ✔ | |

| បច្ចេកវិទ្យា | | ប្រភេទលូ | | | វត្ថុធាតុដើមលូ | អង្កត់ផ្ចិតលូ (មីលីម៉ែត្រ) | ចំណុចខ្វះខាតគុណភាព | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ទំនាញផែនដី | លូមេ | ខ្នែងរង | | | ប្រព័ន្ធលូខាងក្នុង | ជញ្ជាំងលូ | ការលេចជ្រាប | ទម្រង់លូ |
| សំឡេង | ឧបករណ៍រាវរកការលេចជ្រាបតាមបណ្ដាញលូ | ✔ | ✔ | | អ្វីក៏បាន | ≥១០០ | | | ✔ | |
| | ប្រព័ន្ធត្រួតពិនិត្យ | | ✔ | | PCCP | ≥៤៥០ | | ✔ | | |
| | សូណា/អ៊ុលត្រាសោន | ✔ | ✔ | | អ្វីក៏បាន | ≥៥០ | ✔ | ✔ | | |
| អគ្គិសនី/អេឡិចត្រូម៉ាញ៉េទិក | ការកំណត់ទីតាំងលេចជ្រាបដោយប្រើអគ្គិសនី | ✔ | ✔ | ✔ | អលោហៈ | ≥៧៥ | | | ✔ | |
| | ដែនចរន្តអគ្គិសនីពីចម្ងាយ | ✔ | ✔ | ✔ | លោហៈ: PCCP | ≥៥០ | | ✔ | ✔ | |
| | ការលេចជ្រាបតាមអត្រាលំហូរម៉ាញ៉េទិក | ✔ | ✔ | ✔ | លោហៈ | ៥០ – ១៤០០ | | ✔ | | |
| ឡាស៊ែរ | ក្រាហ្វិកឡាស៊ែរ | ✔ | ✔ | | អ្វីក៏បាន | ១០០ – ៤០០០ | ✔ | ✔ | | |
| បច្ចេកវិទ្យាថ្មី | ការប្រើកាំរស្មីហ្គាម៉ា -ហ្គាម៉ា | ✔ | ✔ | ✔ | បេតុង | មិនទាន់កំណត់ | | | | ✔ |
| | រ៉ាដាមើលឆ្លងកាត់ដី | ✔ | ✔ | ✔ | អ្វីក៏បាន | មិនទាន់កំណត់ | | | ✔ | ✔ |
| | ទែម៉ូរូបភាពអាំងហ្វ្រា | ✔ | ✔ | ✔ | អ្វីក៏បាន | មិនទាន់កំណត់ | | | ✔ | ✔ |
| | មីក្រូចាំងផ្លាត | ✔ | | | ឥដ្ឋ | មិនទាន់កំណត់ | | ✔ | | ✔ |
| | ការប្រើសំលេងខ្លាំង /SASW | ✔ | | | ឥដ្ឋ/បេតុង | >១៨០០ | | ✔ | | |

ប្រភព: (EPA/600/R-09/049 ខែឧសភា ឆ្នាំ២០០៩) PCCP = លូមូលបេតុង (Prestressed Concrete Cylinder Pipe) SASW = ការវិភាគវិសាលគមន៍រលកផ្ទៃខាងលើ (Spectral Analysis of Surface Waves)

***តារាង ៥. បច្ចេកវិទ្យាត្រួតពិនិត្យបណ្ដាញលូអាចអនុវត្តបានចំពោះលក្ខខណ្ឌប្រទេសកម្ពុជា***

| ល.រ | បច្ចេកវិទ្យា | ការអនុវត្ត | | |
|---|---|---|---|---|
| | | ទំហំលូ | វត្ថុធាតុដើមលូ | ស្ថានភាពលូ |
| ១. | ពន្លឺភ្លើង និងកញ្ចក់ឆ្លុះ | រហូតដល់៣០០ មីលីម៉ែត្រ | អ្វីក៏បាន | ទទេ |
| ២. | កាមេរ៉ាតាមដាន | គ្រប់ទំហំ | អ្វីក៏បាន | ទទេ |
| ៣. | ប្រព័ន្ធសូណា | គ្រប់ទំហំ | អ្វីក៏បាន | ហូរពេញ |



*រូបភាព ៣. ការធ្វើតេស្តដោយប្រើកញ្ចក់ឆ្លុះ និងកញ្ចក់ឆ្លុះមានដង*

បញ្ហាទូទៅដែលតែងជួបប្រទះចំពោះបំពង់លូដែលបានដាក់តាមព្រៃស្ដើងៗ ឬកន្លែងមានស្មៅដុះច្រើន គឺជាឫសដើមឈើដែលបានចាក់ទម្លុះតាមតំណភ្ជាប់លូ ហើយបន្តលូតលាស់ក្នុងលូ។ ការដុះបែបនេះប្រៀបដូចជាឆ្នុកបិទលូឱ្យស្ទះ ដូចបង្ហាញក្នុងរូបភាព ៤។ នៅខាងស្តាំដៃ គឺជារូបភាពបណ្តុំឫសដើមឈើនៅក្នុងលូដែលថតដោយកាមេរ៉ា CCTV។



*រូបភាព ៤. ឫសដើមឈើដុះក្នុងលូ*

ដូចគ្នាដែរ ស្ថានភាពរចនាសម្ព័ន្ធរបស់លូចាស់ៗដូចជាលូឥដ្ឋរាងកោង និងលូបេតុងអាចកំណត់បានដោយការប្រើប្រាស់ការអង្កេតសូណា ដែលអាចផ្តល់រូបភាពពីមុខជញ្ជាំងជារាងគូចខ្យងតាមទិសឈរ ៣៦០ ដឺក្រេជុំវិញអ័ក្សដេកបាន។ រូបភាពទាំងនេះអាចយកមកវិភាគដោយប្រុងប្រយ័ត្ន។ ប្រព័ន្ធនេះក៏ផ្តល់ព័ត៌មានអំពីការផ្លាតចេញ និងការជ្រាបលេចទឹកតាមជញ្ជាំងលូដូចមានបង្ហាញនៅក្នុងរូបភាព ៥ ផងដែរ។



*រូបភាព ៥. ការខូចខាតរចនាសម្ព័ន្ធលូ និងស្ថានភាពប្រេះតាមបណ្ដោយលូ*

## ២.៦ ការត្រួតពិនិត្យ និងការធ្វើតេស្តលូ

ប្រសិនបើរកឃើញថាមានបញ្ហាខុសប្រក្រតីនៅពេលត្រួតពិនិត្យបឋមផ្នែកខាងក្នុង ឬកត់សម្គាល់ឃើញពីផ្នែកខាងក្រៅ វិស្វករថែទាំគួរធ្វើការវិនិច្ឆ័យអំពីភាពបន្ទាន់ និងមូលហេតុនៃភាពខុសប្រក្រតី ហើយបន្ទាប់មកធ្វើការត្រួតពិនិត្យ និងសិក្សាឱ្យបានត្រឹមត្រូវ។ បណ្ដាញលូ និងអណ្ដូងលូភាគច្រើនត្រូវបានត្រួតពិនិត្យដោយប្រើប្រាស់បច្ចេកទេសមួយ ឬច្រើនដូចខាងក្រោម៖

### *២.៦.១ ការត្រួតពិនិត្យដោយភ្នែកទទេ*

ការត្រួតពិនិត្យដោយភ្នែកទទេ គឺជាការត្រួតពិនិត្យតាមរយៈរូបភាព ឬដោយការមើលឃើញដើម្បីរកមើលបញ្ហាខុសប្រក្រតីណាមួយ ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យដោយភ្នែកទទេដោយផ្ទាល់ និងការត្រួតពិនិត្យដោយភ្នែកទទេដោយប្រយោល តាមរយៈការប្រើកាមេរ៉ាមានដងភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍ និងកាមេរ៉ាតាមដាន (CCTV)។

- ***ការត្រួតពិនិត្យអណ្ដូងលូដោយភ្នែកទទេ***

ការត្រួតពិនិត្យអណ្ដូងលូដោយភ្នែកទទេ ត្រូវធ្វើឡើងដោយប្រើភ្នែកពិនិត្យមើលគម្របអណ្ដូងលូ និងស្ថានភាពខាងក្នុងអណ្ដូងលូ។ នៅពេលត្រួតពិនិត្យផ្នែកខាងក្នុងនៃអណ្ដូងលូ អ្នកត្រួតពិនិត្យគួរចូលក្នុងអណ្ដូងលូដោយសុវត្ថិភាពត្រឹមត្រូវ។ ការត្រួតពិនិត្យអណ្ដូងលូដោយភ្នែកទទេផ្ដោតលើចំណុចសំខាន់ដូចខាងក្រោម៖

- ស្ថានភាពផ្ទៃខាងក្នុងអណ្ដូងលូ
- ស្ថានភាពលូនៅផ្នែកខាងលើ និងខាងក្រោមដោយមើលពីអណ្ដូងលូ
- ស្ថានភាពនៃការជ្រាបទឹកក្រោមដីចូលក្នុងលូ

ដើម្បីត្រួតពិនិត្យផ្នែកខាងក្នុងលូតាមរយៈអណ្ដូងលូ គួរតែប្រើកញ្ចក់ឆ្លុះ ឬពន្លឺភ្លើងខ្លាំងដើម្បីអង្កេតមើល ឬគួរប្រើកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍ដើម្បីពិនិត្យមើលបណ្ដាញលូ។

ចំណុចសំខាន់ៗនៃការត្រួតពិនិត្យអណ្ដូងលូដោយភ្នែកទទេ៖

- សុក្រឹតភាពនៃការត្រួតពិនិត្យមានកម្រិតខ្ពស់ដោយសារអ្នកត្រួតពិនិត្យបានអង្កេតជាក់ស្ដែងនូវបញ្ហាខុសប្រក្រតីដោយផ្ទាល់។

- ចំណាយថវិកាតិចជាងបើធៀបជាមួយនឹងការត្រួតពិនិត្យដោយប្រើប្រាស់កាមេរ៉ាទូរទស្សន៍។
- លទ្ធផលនៃការត្រួតពិនិត្យនឹងក្លាយជាទិន្នន័យសម្រាប់ប្រតិបត្តិការ និងថែទាំបណ្តាញលូដ៏សំខាន់បំផុត។

នីតិវិធីនៃការត្រួតពិនិត្យអណ្តូងលូដោយភ្នែកទទេមានបង្ហាញនៅក្នុងរូបភាព ៦។




*រូបភាព ៦. នីតិវិធីនៃការត្រួតពិនិត្យអណ្តូងលូ*

- ***ការត្រួតពិនិត្យអណ្តូងលូដោយកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍មានដង***

កាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍មានដងរួមមាន ដងដំណើរការដែលអាចពន្លូតបាន និងមានបំពាក់កាមេរ៉ា និងអំពូលភ្លើងនៅខាងមុខ។ កាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍មានដងនេះត្រូវដាក់បញ្ចូលទៅក្នុងអណ្តូងលូពីលើដី ហើយអ្នកត្រួតពិនិត្យនៅលើដីអង្កេតមើលអេក្រង់ទូរទស្សន៍ និងមើលផ្នែកខាងក្នុងលូតាមកាមេរ៉ា។ ព័ត៌មានលម្អិតអំពីឧបករណ៍ និងដំណើរការមានបង្ហាញក្នុងរូបភាព ៧។

ការប្រៀបធៀបការត្រួតពិនិត្យអណ្តូងលូដោយភ្នែកទទេ និងដោយប្រើកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍មានបង្ហាញក្នុងតារាង ៦។




*រូបភាព ៧. ការត្រួតពិនិត្យដោយប្រើកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍មានដង*

*តារាង ៦. គុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្រត្រួតពិនិត្យដោយភ្នែកទទេ និងដោយប្រើប្រាស់កាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍*

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| ការត្រួតពិនិត្យមានភាពងាយស្រួល ហើយការអង្កេតអាចធ្វើបានក្នុងរយៈពេលខ្លី។ លើសពីនេះ ទិន្នន័យនៃការត្រួតពិនិត្យអាចកត់ត្រាជារូបភាពបាន។ | វិសាលភាពនៃការត្រួតពិនិត្យមានកម្រិតត្រឹមតែផ្នែកជុំវិញមាត់លូ។ |
| ដោយសារអ្នកត្រួតពិនិត្យធ្វើការនៅលើដី ដូច្នេះគ្មានកង្វះអុកស៊ីសែន ឬឧបទ្ទវហេតុណាមួយដោយសារការធ្លាក់ ហើយការងារគឺមានសុវត្ថិភាព។ | មិនអាចមើលឃើញផ្នែកដែលលយចេញតាមទិសបណ្តោយលូ ឬស្នាមប្រេះតូចៗ។ |
| | ចាប់មិនបានពីស្ថានភាពផ្ទៃជញ្ជាំងលូ (មិនអាចមើលឃើញជញ្ជាំងលូ)។ |

- ***ការត្រួតពិនិត្យដោយប្រើកាមេរ៉ាតាមដាន (CCTV)***

ការត្រួតពិនិត្យដោយប្រើកាម៉េរាតាមដានត្រូវបានប្រើញឹកញាប់បំផុត ព្រោះវាជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពថ្លៃចំណាយក្នុងរយៈពេលវែង និងជាវិធីសាស្ត្រមានប្រសិទ្ធភាពបំផុតក្នុងការពិនិត្យមើលស្ថានភាពខាងក្នុងលូ។ កាមេរ៉ាតាមដាន គឺជាប្រភេទនៃការតាមដានតាមរយៈអេក្រង់ទូរទស្សន៍មួយដែលត្រូវបានរុញតាមបណ្តោយលូដោយឧបករណ៍បញ្ជា ដែលប្រើភ្លើងតពីរថយន្តត្រួតពិនិត្យ បន្ទាប់មកកាមេរ៉ានេះចូលតាមបណ្តោយលូ រួចបញ្ជូនរូបភាពនៅក្នុងកាមេរ៉ាទៅអេក្រង់

ទូរទស្សន៍នៅក្នុងរថយន្តត្រួតពិនិត្យវិញ។ ការត្រួតពិនិត្យដោយប្រើ CCTV អាចដំណើរការទៅបាន ជាមួយបណ្តាញលូដែលមានអង្កត់ផ្ចិតចាប់ពី ១៥០ – ១២០០ មីលីម៉ែត្រ។ លូដែលមានអង្កត់ផ្ចិតធំជាងនេះ ក៏អាចត្រួតពិនិត្យដោយ CCTV ផងដែរ។

ជាទូទៅ ការត្រួតពិនិត្យដោយប្រើ CCTV អាចប្រើប្រាស់សម្រាប់គោលបំណងជាច្រើនដូចជា៖

- នៅពេលដែលអ្នកម៉ៅការ ឬទីភ្នាក់ងារសំណង់ទទួលខុសត្រូវកែតម្រូវចំណុចខ្វះខាតនៅក្នុងលូថ្មីមុនពេលទទួលយក។
- នៅពេលដែលអ្នកម៉ៅការ ឬទីភ្នាក់ងារសំណង់កំណត់ ឬផ្ទៀងផ្ទាត់ទីតាំងពិតប្រាកដនៃតំណភ្ជាប់ និងចំណុចសាងសង់លូផ្សេងទៀត ហើយកែតម្រូវផែនទីដែលត្រូវធ្វើតាមការចាំបាច់។
- នៅពេលដែលអ្នកម៉ៅការ ឬទីភ្នាក់ងារសំណង់កំណត់អាទិភាពសម្រាប់ការងារកែតម្រូវនៅក្នុងលូចាស់ "តាមការចាំបាច់" ដើម្បីធានានូវប្រសិទ្ធភាព និងការសន្សំសំចៃខ្ពស់បំផុតសម្រាប់កម្មវិធីថែទាំបង្ការ នូវឧបករណ៍ និងកម្លាំងពលកម្ម ហើយមានវិសាលភាពលើបណ្តាញប្រមូលទឹកកខ្វក់ទាំងមូល។
- ត្រួតពិនិត្យស្ថានភាពនៃការសាងសង់តំណភ្ជាប់ទៅនឹងបណ្តាញលូខ្នែងរង និងលូខ្នែង។ តាមរយៈការអង្កេតមើលតំណភ្ជាប់ទាំងនោះ អាចកំណត់បានប្រសិនបើមានការជ្រាបទឹក ឫសដើមឈើ កំណរកម្ទេចកម្ទី និងប្រភេទផ្សេងៗដែលហូរចូលក្នុងលូ ហើយអាចមានផលប៉ះពាល់អវិជ្ជមានដល់សមត្ថភាពបង្ហូរទឹករបស់លូ។

សមាសធាតុនៃប្រព័ន្ធ CCTV ដែលត្រូវបានបំពាក់ភ្ជាប់ក្នុងរថយន្តវ៉ែន ឬរ៉ឺម៉កសណ្តោង រួមមាន៖ កាមេរ៉ាទូរទស្សន៍ ភ្លើងកាមេរ៉ា ដុំខ្សែភ្លើង និងឈុតថតវីដេអូ អេក្រង់ទូរទស្សន៍សំរាប់តាមដានមើលរូបភាព មជ្ឈមណ្ឌល ឬម៉ូឌុលប្រព័ន្ធគ្រប់គ្រងថាមពល ប្រភពថាមពលចល័ត ជើងដាក់ កាមេរ៉ា ដៃរ៉ៃទាញកាមេរ៉ា ដៃរ៉ៃបញ្ជូនកាមេរ៉ាមកវិញ អេក្រង់រាប់ជំហាន ប្រព័ន្ធទូរស័ព្ទទំនាក់ទំនងប្រើថាមពលសំឡេង ខ្សែអណ្តែតតាមបណ្តោយលូ ដុំខ្សែ TV ដែលមានដុំខ្សែភ្លើង ឧបករណ៍ថតវីដេអូ និងដុំហ្វីលវីដេអូ (អង្គចងចាំ)។

ការដំឡើងកាមេរ៉ា CCTV ត្រូវដាក់កញ្ចក់កាមេរ៉ានៅជិតចំណុចកណ្តាលលូបំផុតតាមដែលអាចធ្វើទៅបាន។ ក្នុងលូធំៗ កាមេរ៉ា និងភ្លើងត្រូវដាក់ភ្ជាប់ជាមួយបន្ទះបណ្តែត ដែលអណ្តែតឆ្លងកាត់លូចាប់ពីអណ្តូងលូមួយទៅអណ្តូងលូបន្ទាប់។ ដើម្បីមើលព័ត៌មានលម្អិតនៃជញ្ជាំងលូ កាមេរ៉ា និងភ្លើងអាចបង្វិលបានទាំងតាមទិសឈរ និងដេក។ នៅក្នុងលូតូចៗ ខ្សែ និងកាមេរ៉ាត្រូវភ្ជាប់ជាមួយកូនឡានតូចដែលមានភ្ជាប់ឆ័ត្រយោង ឬឆ័ត្រយោងតូច ហើយអណ្តែតពីអណ្តូងលូមួយទៅអណ្តូងលូបន្ទាប់។ រូបភាពនៃការត្រួតពិនិត្យដោយប្រើកាមេរ៉ា CCTV និងនីតិវិធីត្រួតពិនិត្យមានបង្ហាញរៀងគ្នានៅក្នុងរូបភាព ៨ និងរូបភាព ៩។




*រូបភាព ៨. ការត្រួតពិនិត្យលូដោយប្រើកាមេរ៉ា CCTV*




*រូបភាព ៩. ដំណើរការសម្រាប់ការត្រួតពិនិត្យលូដោយប្រើកាមេរ៉ា CCTV*

### ២.៦.២ ការត្រួតពិនិត្យរកការជ្រាបទឹក

ប្រសិនបើមានការការជ្រាបទឹកក្នុងបណ្តាញលូ នោះប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មអាចនឹងទទួលរងផលប៉ះពាល់ជាអវិជ្ជមាន។ កត្តានេះក៏នាំឱ្យមានកំណើនថ្លៃចំណាយប្រព្រឹត្តកម្មទៅលើស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ (STP) ផងដែរ។ មូលហេតុនៃការជ្រាបទឹកនេះអាចបណ្តាលមកពីបណ្តាញលូមិនគ្រប់គ្រាន់ ឬប្រព័ន្ធបង្ហូរទឹកមិនគ្រប់គ្រាន់។ ករណីនេះ ការត្រួតពិនិត្យតំណភ្ជាប់លូនៅតាមផ្ទះ ការត្រួតពិនិត្យអត្រាលំហូរទឹក និងការត្រួតពិនិត្យភាពមិនជ្រាបទឹកចាំបាច់ត្រូវតែធ្វើរួមគ្នា ហើយមូលហេតុនៃការជ្រាបទឹកក៏គួរតែត្រួតពិនិត្យរកមើលផងដែរ។ ការត្រួតពិនិត្យលំហូរទឹកអាចជួយប្រមូលទិន្នន័យសំខាន់ៗសម្រាប់ការកែលម្អ និងកែសម្រួលប្រព័ន្ធលូ។

- ***ការត្រួតពិនិត្យតំណភ្ជាប់លូនៅតាមផ្ទះ***

ត្រូវធ្វើការការត្រួតពិនិត្យដើម្បីមើលថាឧបករណ៍បង្ហូរទឹកភ្លៀង មិនត្រូវបានតភ្ជាប់ជាមួយលូនៅក្នុងប្រព័ន្ធលូដាច់ដោយឡែកឡើយ។ វិសាលភាពនៃការងារនេះគឺ រាប់ចាប់ពីការងារលូមេនៃប្រព័ន្ធលូ រហូតដល់ប្រព័ន្ធបង្ហូរទឹកតាមផ្ទះ។

ជាទូទៅ ការត្រួតពិនិត្យតំណភ្ជាប់លូនៅតាមផ្ទះមានវិធីសាស្រ្តចំនួនបីដូចជា៖ ការធ្វើតេស្តដោយប្រើផ្សែង ការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង និងការធ្វើតេស្តដោយការចាក់ទឹកពណ៌។

- ***ការធ្វើតេស្តដោយប្រើផ្សែង***

ការធ្វើតេស្តដោយប្រើផ្សែង គឺជាដំណើរការធម្មតាដែលរួមមានការផ្លុំផ្សែងដោយប្រើខ្យល់ខ្លាំងចូលទៅក្នុងបណ្តាញលូបង្ហូរទឹកកខ្វក់ដែលជាទូទៅបាញ់ចូលតាមអណ្តូងលូ។ ផ្សែងនឹងដាលចេញតាមកន្លែងដែលមានភាពធន់តិចតួចបំផុត និងបង្ហាញយ៉ាងលឿននៅកន្លែងដែលមានទឹកលើដីហូរចូល។ ផ្សែងនឹងកំណត់ទីតាំងអណ្តូងលូដែលបែក តំណភ្ជាប់ខុសច្បាប់ រួមមាន លូបង្ហូរទឹកភ្លៀងពីដំបូល ម៉ូទ័របូមទឹកចេញ និងការបង្ហូរទឹកពីទីធ្លា បណ្តាញលូគ្មានគម្រប ស្នាមប្រេះនៅបណ្តាញលូមេ និងបណ្តាញលូខ្នែងរង តាមរយៈផ្សែងដែលដាលទៅកាន់ផ្ទៃទាំងនោះ។ ការធ្វើតេស្តដោយប្រើផ្សែងជាវិធីសាស្រ្តមួយសម្រាប់ត្រួតពិនិត្យទាំងបណ្តាញលូមេ និងបណ្តាញលូខ្នែងរង។ ផ្សែងដាលទៅកាន់គ្រប់កន្លែងទាំងអស់នៃបណ្តាញលូ ដោយកំណត់បញ្ហាដែលមាននៅក្នុងបណ្តាញលូដែលបានតភ្ជាប់ទាំងអស់ ពោលគឺសូម្បីតែផ្នែកនៃបណ្តាញលូដែលមិនដឹងថាមាន ឬគិតថានឹងមានដាច់ដោយឡែក ឬមិនបានតភ្ជាប់ក៏ដោយ។ ការធ្វើតេស្តនេះនឹងទទួលបានលទ្ធផលល្អបំផុតនៅពេលធាតុអាកាសក្តៅ ដែលអនុគ្រោះផ្សែងឱ្យដាលបានកាន់តែប្រសើរទៅកាន់ផ្ទៃនានានៃប្រព័ន្ធលូ។

ឧបករណ៍ចាំបាច់ប្រើប្រាស់សម្រាប់ដំណើរការនៃការធ្វើតេស្តដោយប្រើផ្សែងនេះ គឺជាម៉ូទ័រផ្លុំ ម៉ាស៊ីន/សម្ភារៈបញ្ចេញផ្សែង (រូបភាព ១០) ។ ផ្សែងដែលអាចរកបាននាពេលបច្ចុប្បន្នសម្រាប់ការធ្វើតេស្តនេះមានពីរប្រភេទ៖ ទៀនផ្សែង និងសារធាតុរាវបញ្ចេញផ្សែង។ ព័ត៌មានលម្អិតអំពីឧបករណ៍នីមួយៗមានបង្ហាញដូចខាងក្រោម៖

- ម៉ូទ័រផ្លុំមានរាងដូចគូទខ្យងចាក់សាំង និងមានខ្សែពានទាញ។ សមត្ថភាពជាមធ្យមនៃម៉ូទ័រផ្លុំមានកម្លាំងជាង ៣,០០០ម៉ែត្រគូប/ម៉ោង និងក្រោម ៥,០០០ម៉ែត្រគូប/ម៉ោង។ ម៉ូទ័រផ្លុំមានបាតដែលមានរ៉ងកៅស៊ូនៅពីក្រោមបាត ដែលអាចឱ្យវាបញ្ចេញ និងប្រើកម្លាំងបាញ់ខ្យល់ចូលទៅក្នុងអណ្តូងលូចំហ។
- ទៀនផ្សែងត្រូវបានប្រើដោយគ្រាន់តែដាក់នៅខាងផ្នែកបឺតខ្យល់ចូលរបស់ម៉ូទ័រផ្លុំ។ នៅពេលឆេះ ផ្សែងដែលបញ្ចេញនោះត្រូវបានស្រូបចូលទៅជាមួយខ្យល់ធម្មជាតិហើយបាញ់ចូលទៅតាមអណ្តូងលូ និងនៅក្នុងបណ្តាញលូទាំងមូល។ ទៀនផ្សែងអាចរកទិញបានតាមទំហំផ្សេងៗដែលអាចយកទៅប្រើប្រាស់ម្តងមួយៗ ឬប្រើច្រើនដើមបញ្ចូលគ្នាតាមតម្រូវការផ្សេងៗគ្នា។ ផ្សែងប្រភេទនេះ ត្រូវបានបង្កើតឡើងដោយប្រតិកម្មគីមីដែលបង្កើតបានផ្សែង ដែលមានផ្ទុកបរិមាណសំណើមបរិយាកាសខ្ពស់។ ផ្សែងនេះអាចមើលឃើញសូម្បីតែនៅកំហាប់ទាបក៏ដោយ ហើយមានប្រសិទ្ធភាពខ្ពស់ក្នុងការស្វែងរកកន្លែងលេចជ្រាប។
- ប្រភពផ្សែងមួយទៀតគឺជាប្រព័ន្ធសារធាតុរាវបង្កើតផ្សែង។ ប្រព័ន្ធសារធាតុរាវបង្កើតផ្សែងនេះត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ប៉ុន្តែសំខាន់ត្រូវយល់ពីរបៀបដែលប្រព័ន្ធនេះដំណើរការ។ ប្រព័ន្ធនេះ ទាក់ទងនឹងការចាក់បញ្ចូលសារធាតុរាវបង្កើតផ្សែង ដែលជាទូទៅគឺជាប្រភេទផលិតផលតន្ទូនៈ ទៅក្នុងប្រព័ន្ធបញ្ចេញខ្យល់ក្តៅនៃម៉ាស៊ីនដែលត្រូវបានដុតកម្តៅនៅក្នុងបំពង់ស៊ីម៉ាំង (ឬបន្ទប់ចំហេះ) ហើយបញ្ចេញទៅក្នុងផ្នែកបឺតខ្យល់ចូលនៃម៉ូទ័រផ្លុំ។ ជាទូទៅ សារធាតុរាវបង្កើតផ្សែងមួយហ្គាឡុងមានតម្លៃថោកជាងទៀនផ្សែង ១២ ដើម។ ប៉ុន្តែ សារធាតុរាវបង្កើតផ្សែងមិនអាចបង្កើតផ្សែងដែលមានគុណភាពដូចៗគ្នាឡើយ។ នៅពេលប្រើសារធាតុបង្កើតផ្សែង ប្រការសំខាន់ដែលត្រូវយល់គឺសារសារធាតុរាវបង្កើតផ្សែង ត្រូវចាក់បញ្ចូលទៅក្នុងបន្ទប់ចំហេះ (ឬបំពង់ស៊ីម៉ាំង) នោះវានឹងចាប់ផ្តើមធ្វើឱ្យម៉ូទ័រចុះត្រជាក់ភ្លាមៗ។ បន្ទប់ចំហេះនឹងឈានទៅរកចំណុចមួយដែលមានកម្តៅមិនគ្រប់គ្រាន់ ដើម្បីបំប្លែងសារធាតុរាវទាំងអស់ឱ្យទៅជាផ្សែង ដែលជាលទ្ធផលនឹងបង្កើតឱ្យមានផ្សែងស្តើង/ផ្សែងសើម។ ស្ថានភាពនេះអាចកើតឡើងភ្លាមៗអាស្រ័យលើអត្រានៃលំហូរសារធាតុរាវ។ ប្រសិនបើផ្សែងមានសភាពស្តើង អាចមានការលំបាកក្នុងការមើលពីចម្ងាយ។ ដូច្នេះ ត្រូវបិទមុខកាត់នៃបណ្តាញលូក្នុងករណីប្រើប្រាស់ប្រភេទផ្សែងណាមួយ ប៉ុន្តែនៅពេលប្រើសារធាតុរាវបង្កើតផ្សែង ការបិទនេះគឺជាករណីចាំបាច់។




*រូបភាព ១០. សម្ភារៈប្រើប្រាស់សម្រាប់ការងារតេស្តដោយប្រើផ្សែង (A) ម៉ូទ័រផ្លុំផ្សែងនៅអណ្តូងលូ (B) ទៀនផ្សែង (C) សារធាតុរាវបង្កើតផ្សែង*

គំនូសព្រាងអំពីការធ្វើតេស្តដោយប្រើផ្សែង និងនីតិវិធីការងារសង្ខេបមានបង្ហាញនៅក្នុងរូបភាព ១១ និង ១២។




*រូបភាព ១១. គំនូសព្រាងបង្ហាញអំពីការធ្វើតេស្តដោយប្រើផ្សែង*




*រូបភាព ១២. នីតិវិធីដំណើរការសម្រាប់ការធ្វើតេស្តដោយប្រើផ្សែង*

- ***ការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង***

គឺជាវិធីសាស្ត្រមួយដើម្បីបញ្ជាក់ថាប្រព័ន្ធលូត្រូវបានតភ្ជាប់បានត្រឹមត្រូវ ហើយក៏ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីដឹងអំពីប្រព័ន្ធទុយោ ព្រមទាំងផ្លូវលូ និងលូខ្វែងរង។ រលកសំឡេងអ៊ុលត្រាសូនិក (ឧបករណ៍បញ្ជូន និងឧបករណ៍ទទួល) ត្រូវបានប្រើប្រាស់។ គំនូសព្រាងអំពីវិធីសាស្ត្រធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង និងនីតិវិធីការងារមានបង្ហាញនៅក្នុងរូបភាព ១៣ និង១៤។

លក្ខណៈនៃការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេងរួមមាន៖

- វិធីសាស្ត្រធម្មតាដើម្បីបញ្ជាក់ថាលូត្រូវបានតភ្ជាប់ ឬអត់
- មានប្រសិទ្ធភាព ជាពិសេសចំពោះតំណភ្ជាប់លូខ្វែងរង
- មិនអាចវិនិច្ឆ័យការស្ទះ ឬការជាប់គាំង




*រូបភាព ១៣. ការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង*




*រូបភាព ១៤. នីតិវិធីដំណើរការសម្រាប់ការធ្វើតេស្តដោយប្រើចំណាំងផ្លាតសំឡេង*

- *ការធ្វើតេស្តដោយការចាក់ទឹកពណ៌*

ការធ្វើតេស្តដោយការចាក់ទឹកពណ៌ត្រូវបានប្រើប្រាស់ដើម្បីកំណត់ទីតាំងប្រព័ន្ធ ឬឧបករណ៍ជាក់លាក់ណាមួយ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធប្រមូលសំណល់រាវ ឬអត់ កំណត់រកតំណភ្ជាប់មិន

ត្រឹមត្រូវ ព្រមទាំងលូហៀរទឹក ឬលេចជ្រាបទឹក។ ការធ្វើតេស្តដោយការចាក់ទឹកពណ៌ក្នុងលូនេះក៏ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីអន្តរតំណភ្ជាប់រវាងបណ្តាញលូបង្ហូរទឹកកខ្វក់ និងបណ្តាញលូបង្ហូរទឹកភ្លៀង។ ថ្នាំពណ៌ពិសេសនេះ អាចរកទិញបានសម្រាប់ការធ្វើតេស្តប្រភេទនេះ។

ឧទាហរណ៍ទូទៅអំពីការធ្វើតេស្តដោយការចាក់ពណ៌ក្នុងទឹករួមមាន៖ អគារដែលមិនបង្ហាញផ្សែងតាមរន្ធខ្យល់ចេញចូលក្នុងពេលធ្វើតេស្តដោយប្រើផ្សែងដោយសារការធ្លាក់ចុះ ឬស្ទះនៅក្នុងលូតំណភ្ជាប់កំពុងប្រើប្រាស់ លូបង្ហូរទឹកពីទីធ្លារ ឬលូបង្ហូរទឹកភ្លៀងត្រូវបានសង្ស័យថា តភ្ជាប់ជាមួយលូអគារ ឬលូខ្វែងរង ព្រមទាំងស្ថានភាពសង្ស័យនៃលំហូរទឹក ឬការហូរទឹកលើដីចូលទៅលូប្រមូល។

ការប្រើប្រាស់ផ្សេងៗទៀតនៃការធ្វើតេស្តដោយការចាក់ទឹកពណ៌នេះរួមមាន ការវាយតម្លៃអំពីល្បឿនលំហូរទឹក និងការធ្វើតេស្តរកការជ្រាបចូល និងការជ្រាបចេញ។ តាមរយៈការទាញថង់ថ្នាំពណ៌ឡើងលើលូ ហើយឈប់មួយភ្លែត គេអាចកំណត់ទីតាំងសណ្តកចេញដែលមិនអាចមើលឃើញនៅពេលត្រួតពិនិត្យដោយប្រើកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍ដូចជា តំណភ្ជាប់ចំហដែលនៅតាមបណ្តោយលូ និងនៅត្រង់កន្លែងប៉ោងឡើង។

ដើម្បីអនុវត្តការធ្វើតេស្តដោយការចាក់ទឹកពណ៌ឱ្យបានល្អ សហការីម្នាក់ចាក់ទឹកពណ៌នៅទីតាំងសង្ស័យ សហការីម្នាក់ទៀត ត្រូវចាំមើលនៅអណ្តូងលូខាងក្រោមបន្ទាប់ពីទីតាំងនោះ។ ប្រសិនបើមានប្រើប្រាស់ឧបករណ៍តភ្ជាប់ទុយោទឹកដូចជាបង្គន់ ឬចានលាងដៃ ត្រូវកាច់បើកទឹក ហើយម្សៅ ឬគ្រាប់ថ្នាំពណ៌ត្រូវទម្លាក់ដោយផ្ទាល់នៅក្នុងទឹកទុយោបង្ហូរទឹក។ ប្រសិនបើគ្មានប្រភពផ្គត់ផ្គង់ទឹកភ្លាមៗទេ ដូចជាទឹកភ្លៀង ឬលូបង្ហូរទឹកភ្លៀងនៅក្នុងរដូវប្រាំង ត្រូវចាក់ទឹកមួយធុងលាយជាមួយម្សៅថ្នាំពណ៌នេះ។ បរិមាណទឹក និងថ្នាំពណ៌ដែលត្រូវការអាស្រ័យទៅលើចម្ងាយទៅកាន់អណ្តូងលូបន្ទាប់ និងលំហូរទឹកដែលមានស្រាប់។ ដោយផ្អែកលើល្បឿនសន្ទុះនៃលំហូរនេះ ការសន្ទុះ មួយអាចត្រូវបានធ្វើឡើងទៅតាមរយៈពេលលំហូរដែលបានរំពឹងទុកទៅកាន់អណ្តូងលូខាងក្រោម។ អាចទុកពេលយូរបន្តិចបាន ដោយសារថ្នាំពណ៌ត្រូវចំណាយពេលច្រើនជាងការរំពឹងទុក។ នៅពេលមានការធ្វើតេស្តដោយការចាក់ទឹកពណ៌ជាបន្តបន្ទាប់ទៅក្នុងប្រព័ន្ធលូ ឬផ្នែកនៃប្រព័ន្ធលូតែមួយ ការធ្វើតេស្តដោយការចាក់ទឹកពណ៌នេះ គួរតែចាប់ផ្តើមនៅទីតាំងខាងក្រោមឆ្ងាយបំផុត ហើយ បន្តធ្វើការងារនេះទៅកាន់ទីតាំងខាងលើ សម្រាប់ការធ្វើតេស្តដោយការចាក់ទឹកពណ៌ផ្សេងទៀត។ ផ្ទុយទៅវិញ ប្រសិនបើអ្នកចាក់ទឹកពណ៌នៅទីតាំងខាងលើមុន នោះត្រូវរង់ចាំលំហូរទឹកជាច្រើនម៉ោង ឬរហូតដល់ថ្ងៃបន្ទាប់ដើម្បីធ្វើតេស្តបន្តទៀត។ វិធីសាស្ត្រនៃការធ្វើតេស្តដោយការចាក់ទឹកពណ៌មានបង្ហាញនៅក្នុងរូបភាព ១៥។




*រូបភាព ១៥. រូបអំពីការធ្វើតេស្តដោយការចាក់ទឹកពណ៌*

## ២.៦.៣ ការត្រួតពិនិត្យអត្រាលំហូរទឹក

ការកំណត់អត្រាលំហូរគួរតែធ្វើឡើងនៅទីតាំងដែលអាចមានការជ្រាបទឹកចូលខ្ពស់ឧទាហរណ៍ កន្លែងដែលមានកម្រិតនីវ៉ូទឹកក្រោមដីខ្ពស់ ត្រង់ចំណុចប្រសព្វនៃទន្លេ ឬនៅទីតាំងជាប់នឹងទន្លេ។

- ***ការវាស់វែងអត្រាលំហូរទឹក***

លំហូរទឹកអាចវាស់វែងបានភ្លាមៗ ឬជាប្រចាំ។ ប្រព័ន្ធតាមដានជាប្រចាំ រួមមានឧបករណ៍វាស់វែងលំហូរបឋម ឧបករណ៍ចាប់សញ្ញាលំហូរ ឧបករណ៍បញ្ជូនសញ្ញា ឧបករណ៍កត់ត្រាលំហូរ និងឧបករណ៍វាស់វែងលំហូរសរុប។ រង្វាស់លំហូរភ្លាមៗអាចទទួលបានតាមរយៈការប្រើឧបករណ៍វាស់វែងលំហូរបឋម។

ចំណុចសំខាន់បំផុតនៃប្រព័ន្ធវាស់វែងលំហូរជាប្រចាំ គឺឧបករណ៍វាស់វែងលំហូរបឋម។ ឧបករណ៍នេះបង្កើតឡើងដើម្បីផលិតការឆ្លើយតបអ៊ីដ្រូលីកដែលអាចព្យាករណ៍បាន ពាក់ព័ន្ធនឹងអត្រាលំហូរនៃទឹក ឬសំណល់រាវដែលហូរកាត់តាមឧបករណ៍នេះ។ ឧទាហរណ៍ខ្លះៗនៃឧបករណ៍ទាំងនេះ រួមមានទំនប់ទាបៗ និងប្រឡាយដែលវាស់ជម្រៅទឹក (ក្បាល) ដែលហូរ ម៉ែត្រប្រភេទ Venturi[1] និង Orifice[2] សម្រាប់វាស់សម្ពាធឌីហ្វេរ៉ង់ស្យែលដែលហូរ ព្រមទាំងវាស់លំហូរម៉ាញ៉េទិច ដែលវាស់តង់ស្យុងអគ្គិសនីដែលហូរ។ ឧបករណ៍វាស់លំហូរបឋមស្តង់ដារទាំងនេះ អាចវាស់បានសុក្រឹត្យល្អ ប្រសិនបើតំឡើង និងធ្វើឡើងស្របតាមស្តង់ដារដែលបានកំណត់។

ត្រូវមានឧបករណ៍ចាប់សញ្ញាលំហូរដើម្បីវាស់ការឆ្លើយតបអ៊ីដ្រូលីកជាក់លាក់ពីឧបករណ៍វាស់លំហូរបឋម ហើយបញ្ជូនការឆ្លើយតបនេះទៅកាន់ប្រព័ន្ធកត់ត្រា។ ជាធម្មតា ឧបករណ៍ចាប់សញ្ញារួមមានឧបករណ៍បញ្ជូនសំឡេងអ៊ុលត្រាសូនិក ពោងបណ្តែត ឧបករណ៍បំលែងថាមពល

[1] ឧបករណ៍វាស់ល្បឿនលំហូរនៃសារធាតុរាវ ដោយការវាស់ការប្រែប្រួលសម្ពាធពីចំណុចមួយទៅចំណុចមួយទៀត (lenntech.com)
[2] ឧបករណ៍វាស់ល្បឿនលំហូរនៃឧស្ម័ន ឬសារធាតុរាវនៅក្នុងបំពង់ទុយោ (marinerspointpro.com/orifice-meter)

សម្ពាធ ឧបករណ៍វាស់សំណើមដី (capacitance probes[3]) ឧបករណ៍វាស់សម្ពាធឌីហ្វេរ៉ង់ស្យែល ឧបករណ៍អេឡិចត្រូម៉ាញ៉េទិកជាដើម។ ជាទូទៅ សញ្ញាពីឧបករណ៍ចាប់សញ្ញាត្រូវបានបំលែងដោយប្រព័ន្ធមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិកទៅជាឯកតាលំហូរដែលត្រូវកត់ត្រាដោយផ្ទាល់នៅក្នុងតារាង ឬបញ្ជូនចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ ជាទូទៅ ប្រព័ន្ធដែលប្រើឧបករណ៍កត់ត្រាមានបំពាក់ឧបករណ៍វាស់លំហូរសរុបដែលបង្ហាញតាមពេលវេលាជាក់ស្តែង។

ការពិចារណាសំខាន់មួយសម្រាប់អ្នកសង្កេតអំឡុងពេលសិក្សាអំពីសំណល់រាវ គឺទទួលបានទិន្នន័យលំហូរជាប្រចាំនៅទីតាំងមួយ ដែលត្រូវយកតែទិន្នន័យលំហូរទឹកភ្លាមៗប៉ុណ្ណោះ។ ប្រសិនបើឧបករណ៍វាស់លំហូរបឋមនៅបណ្តាញលូបើកត្រូវបានប្រើប្រាស់ដើម្បីវាស់ភ្លាមៗនោះ ចាំបាច់ត្រូវតំឡើងតែឧបករណ៍ចាប់សញ្ញាតាមទីតាំង និងឧបករណ៍កត់ត្រាចល័តប៉ុណ្ណោះ។

ជាទូទៅ ប្រព័ន្ធវាស់វែងលំហូរសំណល់រាវមានសុក្រឹត្យភាពណាស់។ ប្រព័ន្ធវាស់វែងលំហូរជាប្រចាំណាដែលមិនអាចវាស់វែងលំហូរសំណល់រាវនៅកម្រិត±១០ភាគរយនៃលំហូរជាក់ស្តែង ត្រូវចាត់ទុកថាមិនអាចទទួលយកបានសម្រាប់ការប្រើប្រាស់ក្នុងការវាស់វែងលំហូរសំណល់រាវទេ។

- ***ការធ្វើតេស្តដោយការបូម***

ជាវិធីសាស្ត្រវាស់វែងអត្រាលំហូរទឹកដែលបានជ្រាបចូលបណ្តាញលូ។ អត្រាលំហូរទឹកដែលបានជ្រាបចូលទៅក្នុងកន្លែងណាមួយ ឬប្រព័ន្ធលូអាចដឹងបានក្នុងរយៈពេលខ្លី។ ប៉ុន្តែ អត្រាលំហូរទឹកដែលបានជ្រាបចូលមានភាពខុសគ្នាទៅតាមការប្រែប្រួលនៃទឹកក្រោមដី ដូច្នេះហើយទើបការបង្កើតកករ និងធាតុអាកាសនៅពេលវាស់វែងនោះគួរតែត្រូវបានបញ្ជាក់។

ដើម្បីបង្វែរសំណល់រាវតាមផ្ទះចេញពីការធ្វើតេស្តនេះ នៅពេលធ្វើការត្រួតពិនិត្យសម្រាប់កន្លែងនីមួយៗ ត្រូវតំឡើងឆ្នុកសងខាងលូ។ ការអនុវត្តនេះ ជាការល្អគួរតែធ្វើឡើងនៅពេលយប់ដែលជាពេលមានបរិមាណទឹកកខ្វក់តាមផ្ទះតិចតួច។ រូបភាពអំពីការធ្វើតេស្តដោយការបូម និងនីតិវិធីការងារមានបង្ហាញនៅក្នុងរូបភាព ១៦ និងរូបភាព ១៧ ។




**រូបភាព ១៦. ដ្យាក្រាមនៃការធ្វើតេស្តដោយការបូម**

---
[3] ឧបករណ៍នេះត្រូវបានប្រើប្រាស់នៅក្នុងវិស័យកសិកម្មសម្រាប់កំណត់ពីពេលវេលានៃការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ (en.wikipedia.org/capacitance_probe)

លក្ខណៈនៃការវាស់វែងអំឡុងពេលធ្វើតេស្តដោយការបូមរួមមាន៖

- អត្រាលំហូរនៃទឹកក្រោមដីដែលបានជ្រាបចូលសម្រាប់ទីកន្លែង ឬប្រព័ន្ធលូនីមួយៗ អាចវាស់វែងបាននៅក្នុងរយៈពេលខ្លី។
- តម្លៃដែលបានវាស់វែងមានភាពខុសគ្នាខ្លាំងដោយសារការប្រែប្រួលកម្រិតទឹកក្រោមដី។
- នៅពេលវាស់វែងកន្លែងច្រើន ឬប្រព័ន្ធលូនីមួយៗ មានការលំបាកក្នុងការបញ្ចេញចោលសំណល់រាវពីតាមផ្ទះចេញនៅពេលយប់ជ្រៅ។
-




*រូបភាព ១៧. នីតិវិធីការងារនៃការធ្វើតេស្តដោយការបូម*

### ២.៦.៤ ការត្រួតពិនិត្យការស៊ីរិចរិល និងភាពចាស់ទ្រុឌទ្រោម

ភាពចាស់ទ្រុឌទ្រោម ឬការស៊ីរិចរិលនៅក្នុងលូគួរតែវិនិច្ឆ័យដោយកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍។ វត្ថុធាតុដើមនៅក្នុងប្រព័ន្ធលូនេះ មានច្រើនប្រភេទផ្សេងៗគ្នាដូចជា៖ លូបេតុង លូសេរ៉ាមិក បំពង់ទីបជ័រ uPVC (រឹង) ឥដ្ឋ ទុយោ HDPE ទុយោយឺត (ductile pipe) និងទុយោ GRP ដូច្នេះ លក្ខខណ្ឌនៃការស៊ីរិចរិល និងភាពចាស់ទ្រុឌទ្រោមក៏មានភាពខុសគ្នាដែរ។

វិធីសាស្រ្តសម្រាប់ការត្រួតពិនិត្យស្ថានភាពការស៊ីរិចរិល និងភាពចាស់ទ្រុឌទ្រោមរបស់លូរួមមាន៖

- ការត្រួតពិនិត្យស្ថានភាពផ្ទៃជញ្ជាំងលូដោយប្រើកាមេរ៉ាភ្ជាប់ជាមួយអេក្រង់ទូរទស្សន៍
- ការត្រួតពិនិត្យរកស្នាមប្រេះ

មូលហេតុនៃការចាស់ទ្រុឌទ្រោមតាមផ្នែកនៃរចនាសម្ព័ន្ធបេតុងនៃប្រព័ន្ធលូមានដូចខាងក្រោម៖

- ស្នាមប្រេះលើបេតុងដោយសារបណ្តុំបន្ទុក (បន្ទុករស់)
- ការចាស់ទ្រុឌទ្រោមរចនាសម្ព័ន្ធដោយសារប្រែប្រួលតាមអាយុកាល

ភាពចាស់ទ្រុឌទ្រោមរចនាសម្ព័ន្ធបេតុង (បេតុងសឹក) ដោយសារអាស៊ីតស៊ុលផួរិចកើតចេញពីអ៊ីដ្រូសែនស៊ុលហ្វីត។ នៅក្នុងទីតាំងមួយដែលមានដក់ទឹកកខ្វក់រយៈពេលយូរ ទឹកកខ្វក់នឹងគ្មានអុកស៊ីសែន ដែលអាចបង្កើតជាស៊ុលហ្វីត ហើយនាំឱ្យបេតុងសឹករិចរិល ដោយសារតែស៊ុលហ្វីតនេះបង្កើតជាអាស៊ីតស៊ុលផួរិច។ ទីតាំងដែលនាំឱ្យបេតុងអាចសឹករិចរិលនៅក្នុងប្រព័ន្ធលូមានដូចខាងក្រោម៖

- បណ្តាញលូនៅទីតាំងបញ្ចេញចោលដែលទុយោរងសម្ពាធ (រួមទាំងម៉ាស៊ីនបូមអណ្តូងលូ)
- គែមខាងលើ និងខាងក្រោមនៃទីតាំងដែលមានការបញ្ចេញទឹកកខ្វក់រួម។
- គែមខាងលើ និងខាងក្រោមនៃទីតាំងដែលមានការបញ្ចេញទឹកកខ្វក់មានផ្ទុកស៊ុលហ្វីត។
- ទីតាំងខាងក្រោមនៃស៊ីហ្វុងផ្កាប់។

ការកំណត់វត្តមានឧស្ម័នអ៊ីដ្រូសែនស៊ុលហ្វីត និងឧស្ម័នដែលបង្កគ្រោះថ្នាក់ផ្សេងៗទៀត គឺជាដំណាក់កាលសំខាន់ នៅពេលគម្របអណ្តូងលូបើកចំហ និងមុនពេលចាប់ផ្តើមត្រួតពិនិត្យ។ ឧបករណ៍ចាប់សញ្ញាយូរដៃត្រូវបានដាក់ចុះទៅក្នុងបណ្តាញលូដើម្បីវាស់កំហាប់ឧស្ម័ន។ ចំពោះលូដែលមានទំហំធំ និងប្រវែងវែង ត្រូវតំឡើងឧបករណ៍វាស់ឧស្ម័ន $H_2S$ ដើម្បីវាស់វែងកំហាប់ $H_2S$ ដែលលើស។ ឧបករណ៍វាស់ឧស្ម័នយូរដៃអាចវាស់ឧស្ម័នផ្សេងៗទៀតជាច្រើនដូចមានបង្ហាញក្នុងតារាង ៧។ រដ្ឋបាលក្រុង ស្រុកជាអ្នកជ្រើសរើសឧបករណ៍វាស់ឧស្ម័ន ដែលយ៉ាងហោចណាស់អាចវាស់កំហាប់ $H_2S$ កាបូន ម៉ូណូអុកស៊ីត អុកស៊ីសែន (កង្វះខាត) មេតាន និងអាសូតអុកស៊ីត។

*តារាង ៧. ឧស្ម័នដែលត្រូវវាស់វែងដោយឧបករណ៍កំណត់វត្តមានឧស្ម័ន (អាចខុសគ្នាពីឧបករណ៍មួយទៅមួយ)*

| ឈ្មោះឧស្ម័ន | និមិត្តសញ្ញា | ឯកតា |
|---|---|---|
| កាបូនម៉ូណូអុកស៊ីត | $CO$ | % |
| អ៊ីដ្រូសែនស៊ុលហ្វីត | $H_2S$ | Ppm |
| អុកស៊ីសែន | $O_2$ | % |
| មេតាន | $CH_4$ | ppm |
| អាសូតអុកស៊ីត | $NO_x$ | ppm |

### ២.៦.៥ បម្រុងប្រយ័ត្ន

នៅពេលចូលទៅក្នុងអណ្តូងលូ ត្រូវមានវិធានការសុវត្ថិភាពនៅពេលកំពុងបំពេញការងារដើម្បីធានាសុវត្ថិភាពចរាចរណ៍ បង្ការការខ្វះអុកស៊ីសែន បម្រុងប្រយ័ត្នចំពោះអ៊ីដ្រូសែនស៊ុលហ្វីត។ល។ ដើម្បីធានាសុវត្ថិភាពរបស់បុគ្គលិក ជៀសវាងការលាងសម្អាតលូ/អាងសិបទិចដោយដៃ ព្រោះអ្នកសម្អាតអាចប៉ះពាល់ដោយផ្ទាល់ជាមួយសំណល់ភក់ និងទឹកកខ្វក់។

ដូច្នេះ ចាំបាច់ត្រូវប្រើឧបករណ៍ និងគ្រឿងចក្រសម្អាត។ បន្ថែមពីនេះ ត្រូវចាត់វិធានការសុវត្ថិភាពចាំបាច់មុនពេលចូលទៅក្នុងអណ្តូងលូដើម្បីលាងសម្អាត។

ការបំពុលទឹកស្អាតដោយទឹកកខ្វក់អាចកើតមានឡើង នៅពេលទុយោផ្គត់ផ្គង់ទឹកឆ្លងកាត់អណ្តូងលូ ដែលជាទូទៅនៅតាមផ្លូវតូចចង្អៀត ជាពិសេសនៅពេលដែលតំណទុយោផ្គត់ផ្គង់ទឹកស្អាតត្រូវបានបំពាក់ភ្ជាប់នៅក្នុងអណ្តូងលូទឹកកខ្វក់ និងនៅពេលដែលតំណទុយោផ្គត់ផ្គង់ទឹកស្អាតមានការលេចជ្រាប ពេលនោះនឹងអាចមានការបំពុលដល់ទឹកស្អាត។

ដូច្នេះ ប្រព័ន្ធទុយោផ្គត់ផ្គង់ទឹកស្អាត មិនគួរដាក់ភ្ជាប់នៅក្នុងអណ្តូងលូទឹកកខ្វក់ឡើយ។ ប្រសិនបើសង្កេតឃើញមានស្ថានភាពបែបនេះ ត្រូវបិទទុយោផ្គត់ផ្គង់ទឹកស្អាតភ្លាមដើម្បីបញ្ឈប់លំហូរទឹកស្អាត ហើយរកមធ្យោបាយបណ្តោះអាសន្នផ្សេងទៀត ដើម្បីផ្គត់ផ្គង់ទឹកស្អាតដល់សាធារណជនដែលរងផលប៉ះពាល់ ដូចជារថយន្តស៊ីទែនដឹកទឹក ឬការរៀបទុយោទឹកដាច់ដោយឡែកនៅលើដី/នៅលើផ្លូវ ហើយផ្នែកបណ្តាញផ្គត់ផ្គង់ទឹកស្អាតដែលកប់នៅក្នុងអណ្តូងលូត្រូវដកចេញពីអណ្តូងលូមកដាក់ខាងក្រៅវិញ។ ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះប្រព័ន្ធលូបែងចែក ជាពិសេសនៅពេលដាក់ប្រព័ន្ធលូដែលមានប្រហោងតូច ឬប្រើប្រាស់ប្រព័ន្ធលូរាក់។

## ២.៧ បណ្តាញលូតំណតាមផ្ទះ

វិស្វករថែទាំ គួរតែតភ្ជាប់បណ្តាញលូតំណតាមផ្ទះទៅប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធលូក្រុង ហើយការតភ្ជាប់បណ្តាញលូ និងមុខកាត់នៃលូតំណដែលប្រើប្រាស់តាមផ្ទះគឺត្រូវអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។ ប្រសិនបើច្បាប់ ឬបទប្បញ្ញត្តិពុំទាន់មាននៅឡើយទេ ការអនុវត្តការតលូភ្ជាប់គួរត្រូវយោងតាមក្រមប្រតិបត្តិអន្តរជាតិដែលពាក់ព័ន្ធ។ ក្នុងនោះ មុខកាត់បណ្តាញលូតំណតាមផ្ទះមានទំហំអប្បបរមា ១៥០មីលីម៉ែត្រ ហើយបណ្តាញលូតំណតាមផ្ទះគួរតែតភ្ជាប់ទៅលូសាធារណៈ ឬលូក្រុងតាមរយៈអណ្តូងលូ។

ដូចគ្នាដែរ តំណដែលភ្ជាប់ទៅនឹងអណ្តូងលូត្រូវតែធ្វើឱ្យបានល្អ និងបិទជិត។ ត្រូវតែមានការប្រុងប្រយ័ត្នដើម្បីកុំឱ្យមានដុំឥដ្ឋ ឬសម្ភារៈសំណង់ផ្សេងទៀតធ្លាក់ចូលនៅក្នុងអណ្តូងលូ។ ដោយសារតែសម្ភារៈទាំងអស់នោះអាចបណ្តាលឱ្យមានការកកស្ទះបណ្តាញលូ។

ត្រូវតែធានាផងដែរថា ការតភ្ជាប់ក្នុងផ្ទះគឺធ្វើបានជិតត្រឹមត្រូវតាមបច្ចេកទេសដែលមិនបណ្តាលឱ្យលេចធ្លាយឧស្ម័នពីលូចូលទៅក្នុងផ្ទះ ព្រមទាំងកំទេចកំទីធំៗអាចហូរចូលទៅក្នុងលូតំណបានផងដែរ។ ម៉្យាងវិញទៀត វត្ថុរាវ ឬសម្ភារៈណាមួយដែលអាចបណ្តាលឱ្យខូចបណ្តាញលូ ឬបង្គគ្រោះថ្នាក់ដល់កម្មករដែលចូលរួមថែរក្សាបណ្តាញលូ ដូចជាទឹកក្តៅ អាស៊ីត សារធាតុគីមី ជាដើម មិនត្រូវអនុញ្ញាតឱ្យចាក់ចូលក្នុងលូជាដាច់ខាត។

### *២.៧.១ ការត្រួតពិនិត្យ និងការធ្វើតេស្ត*

ការត្រួតពិនិត្យបណ្តាញលូខ្វែងរង និងច្រកមុខទឹកហូរ (ផ្ទះ) គួរតែត្រូវបានអនុវត្តក្នុងករណីចាំបាច់ ដោយយោងតាមឯកសារ និងទិន្នន័យ និងតំណភ្ជាប់លូមេ ក៏ត្រូវត្រួតពិនិត្យផងដែរ។ ត្រូវត្រួតពិនិត្យការស្ទះបណ្តាញលូខ្វែងរង និងកករនៅច្រកមុខទឹកហូរ។

ការធ្វើតេស្តបណ្តាញលូដោយប្រើកាម៉េរ៉ាទូរទស្សន៍គួរតែធ្វើបន្ទាប់ពីការលាងសម្អាតដោយបាញ់ទឹកសម្ពាធខ្ពស់រួចរាល់។ ត្រូវប្រើកាមេរ៉ាទូរទស្សន៍ និងថតទុកជាខ្សែវីដេអូចំពោះការធ្វើតេស្តផ្នែកខាងក្នុងបំពង់លូ។ ការប្រើកាមេរ៉ាទូរទស្សន៍ចំពោះបណ្តាញលូខ្នែងរងសម្រាប់មើលរូបភាពផ្ទាល់ ហើយត្រូវរុញក្បាលកាមេរ៉ាដោយប្រើឧបករណ៍រឹងទៅច្រកមុខទឹកហូរសាធារណៈ។ មានវិធីសាស្ត្រធ្វើតេស្តដោយប្រើខ្សែកាបរឹងរុញចូលជាមួយក្បាលកាមេរ៉ា។ ការធ្វើតេស្តបណ្តាញលូខ្នែងរងតាមផ្ទះដោយប្រើកាមេរ៉ាទូរទស្សន៍មានបង្ហាញនៅរូបភាព ១៨។



*រូបភាព ១៨. ប្រព័ន្ធកាមេរ៉ាចល័តប្រើប្រាស់សម្រាប់ប្រភេទលូមុខកាត់តូច (Source: EPA, 2003) និងការធ្វើតេស្តបណ្តាញលូខ្នែងរងដោយប្រើកាមេរ៉ាទូរទស្សន៍*

លក្ខណៈពិសេសៗនៃការធ្វើតេស្តបណ្តាញលូខ្នែងរងដោយប្រើកាមេរ៉ាទូរទស្សន៍៖

- ប្រសិនបើមានការផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់ រថយន្តដែលផ្ទុកកាមេរ៉ាទូរទស្សន៍អាចដំណើរការបានសូម្បីតែនៅក្នុងទីតាំងដែលមនុស្សមិនអាចចូលទៅបាន។
- តាមរយៈការតភ្ជាប់ម៉ូនីទ័រទៅនឹងរថយន្តដែលផ្ទុកកាមេរ៉ាទូរទស្សន៍ ទិន្នន័យដែលមាន ១៥០ លក្ខណៈខុសគ្នា អាចត្រូវបានបង្ហាញនៅលើអេក្រង់ម៉ូនីទ័រ។
- ចម្ងាយធ្វើតេស្តស្តង់ដារពីទីតាំងមួយក្នុងអំឡុងពេលធ្វើតេស្តបណ្តាញលូខ្នែងរងដោយប្រើកាមេរ៉ាទូរទស្សន៍ជាអតិបរមា ៥ ម៉ែត្រ

នីតិវិធីនៃការធ្វើតេស្តបណ្តាញលូខ្នែងរងដោយកាមេរ៉ាទូរទស្សន៍បង្ហាញក្នុងរូបភាព ១៩។




*រូបភាព ១៩. ដំណើរការនៃការត្រួតពិនិត្យបណ្តាញលូខ្នែងរងដោយប្រើកាមេរ៉ាទូរទស្សន៍*

## ២.៨ ការត្រួតពិនិត្យ និងការធ្វើតេស្តអណ្តូងលូ

### *២.៨.១ អណ្តូងលូ និងឧបករណ៍ផ្សេងទៀត*

ត្រូវត្រួតពិនិត្យ និងយកចិត្តទុកដាក់ក្នុងការថែទាំអណ្តូងលូ ពីព្រោះវាជាផ្នែកមួយនៃបណ្តាញប្រមូលទឹកកខ្វក់។ នៅពេលដែលវាស្ថិតនៅក្បែរផ្លូវ សំណង់អណ្តូងលូត្រូវទទួលរងនូវរំញ័រ និងការសង្កត់ពីចរាចរណ៍របស់រថយន្ត។ អណ្តូងលូអាចស្រុតក្នុងកម្រិតនីវ៉ូណាមួយខុសគ្នា និងបណ្តាលឱ្យប្រេះផងដែរ។ គោលបំណងនៃការត្រួតពិនិត្យអណ្តូងលូគឺដើម្បីកំណត់នូវកម្រិតនីវ៉ូត្រឹមត្រូវ និងពិនិត្យមើលមាត់អណ្តូងលូ និងបញ្ជាក់ថា មាត់អណ្តូងលូមិនត្រូវបានកប់ និងធ្វើតេស្តទម្រង់ទាំងមូល (រកស្នាមប្រេះ) និងសមត្ថភាពបំពេញមុខងារនៃអណ្តូងលូ។ ស្ថានភាពបំពង់លូភ្ជាប់ទៅនឹងអណ្តូងលូអាចដឹងបានដោយការអង្កេតសារធាតុ និងមាឌរបស់លំហូរពីទិសដៅជាក់លាក់ណាមួយ។

### *២.៨.២ ការត្រួតពិនិត្យ និងការធ្វើតេស្ត*

ការត្រួតពិនិត្យ និងធ្វើតេស្តអណ្តូងលូធ្វើឡើងដោយការត្រួតពិនិត្យដោយភ្នែកទទេពីស្ថានភាពនៃគម្រប និងផ្នែកខាងក្នុង។ ការត្រួតពិនិត្យអណ្តូងលូគួរតែអនុវត្តជាមួយនឹងការត្រួតពិនិត្យ និងការធ្វើតេស្តលូ។ ជាទូទៅ ការត្រួតពិនិត្យអណ្តូងលូត្រូវធ្វើជាមួយនឹងការលាងសម្អាតលូ។

### *២.៨.៣ អណ្តូងលូ*

អណ្តូងលូបែកបាក់រារាំងដល់លំហូរ ហើយគឺជាហានិភ័យ។ អ្នកគ្រប់គ្រងអណ្តូងលូគួរតែត្រួតពិនិត្យមើលអណ្តូងលូដែលបែកបាក់ និងគម្របដែលខ្ពស់ជាងផ្លូវ និងការស្ទះអណ្តូងលូជាដើម ដូចបង្ហាញជាឧទាហរណ៍ក្នុងរូបភាព ២០។




*រូបភាព ២០. ឧទាហរណ៍នៃអណ្តូងលូដែលបែកបាក់ (A) គម្របអណ្តូងលូប្រហោង (B) អណ្តូងលូស្ទះ និង (C)កម្ពស់អណ្តូងលូមិនសមស្របទៅនឹងផ្លូវថ្នល់*

### ២.៨.៤ លក្ខខណ្ឌនៅក្នុងអណ្ដូងលូ

អណ្ដូងលូគឺជាហេដ្ឋារចនាសម្ព័ន្ធចាំបាច់ និងជួយសម្រួលដល់ការងារប្រតិបត្តិការ និងថែទាំបណ្ដាញលូដោយសុវត្ថិភាព និងងាយស្រួល។ ដើម្បីឱ្យលំហូរសំណល់រាវទៅតាមលូដោយរលូន ត្រូវត្រួតពិនិត្យចំណុចមួយចំនួនដូចជា ការកាយដល់បាតលូ កករបាតលូ ការស្ទះអណ្ដូងលូ ស្នាមប្រេះនៅក្នុងជញ្ជាំង និងស្ថានភាពនៃតំណលូ។

ការត្រួតពិនិត្យត្រូវធ្វើនៅលើដីនៅនឹងកន្លែង ចំណែកឯការធ្វើតេស្តត្រូវធ្វើដោយមានបុគ្គលិកចុះទៅអណ្ដូងលូ និងធ្វើការនៅក្នុងនោះ។ ចំណុចនីមួយៗដែលត្រូវត្រួតពិនិត្យ និងសេចក្តីបរិយាយមាននៅក្នុងតារាង ៨ និងឧបសម្ព័ន្ធ ១។

*តារាង ៨. ចំណុចផ្សេងៗដែលត្រូវត្រួតពិនិត្យ និងធ្វើតេស្ត*

| ចំណុចដែលត្រូវត្រួតពិនិត្យ | | សេចក្តីបរិយាយពីការត្រួតពិនិត្យ |
|---|---|---|
| ស្ថានភាពខាងក្រៅ | ផ្ទៃខាងលើដី | ក. ពិនិត្យរកស្នាមប្រេះ ស្រុត និង រូងក្នុង<br>ខ. ពិនិត្យរកប្រភពហៀរហូរ<br>គ. ពិនិត្យរកបំពានដោយផ្លូវថ្មើរជើង<br>ឃ. ពិនិត្យមើលស្ថានភាពជុំវិញ |
| | គម្របអណ្ដូងលូ | ក. ពិនិត្យមើលការហូរបញ្ច្រាស់ ការបាក់បែកផ្ទៃខាងលើ និងការស៊ីរិចរិល (ពិនិត្យរកមើលសញ្ញានៅខាងក្រៅ ឬខាងក្នុងរបស់ផ្ទៃខាងលើរបស់គម្របដែលបានរលប់<br>ខ. ពិនិត្យមើលមុខងារការពារភាពអណ្ដែតណាមួយដែលមិនដំណើរការ ឧបករណ៍រាំងស្ទះ មុខងារការពារដែលមិនដំណើរការ ។ល។<br>គ. ចំណុចផ្សេងៗទៀត (ការបែកបាក់នៅផ្ទៃលើ ភាពខុសគ្នានៃកំពស់លូ និងគម្រប ការបែកបាក់គម្របខ្ពស់ គម្របលូបែកចូលអណ្ដូងលូ ភាពមិនដំណើរការផ្សេងៗទៀត ។ល។ |
| ស្ថានភាពខាងក្នុង | លំហូរ និងកំណរ | ក. ពិនិត្យមើលទឹកនឹង ឬទឹកហូរ<br>ខ. ពិនិត្យរកកំណរខ្សាច់ និងដី កំទេចឈើ និងកំណរស៊ីម៉ង់ត៍ និងសំណល់ផ្សេងៗពីកិច្ចការសំណង់ និងការចាក់ចោលខុសច្បាប់<br>គ. ពិនិត្យមើលភាពបញ្ច្រាស់ដែល បែកបាក់ដោយការកោស ។ល។ |
| | ការបែកបាក់ | ក. ពិនិត្យរកកន្លែងស៊ីរិចរិល រញ៉េរញ៉ៃ និងចំនួនសម្ភារៈដែលបាត់បង់<br>ខ. ពិនិត្យរកកន្លែងស្ទះ ប្រេះ ការស៊ីរិចរិល ចន្លោះ និងការខូចខាតដោយការកកស្ទះ |

| ចំណុចដែលត្រូវត្រួតពិនិត្យ | | សេចក្ដីបរិយាយពីការត្រួតពិនិត្យ |
|---|---|---|
| | | គ. ពិនិត្យមើលផុង និងបាតដែលខូច ប្រេះ និងការស៊ីរិចរិល<br>ឃ. ពិនិត្យមើលតំណមិនត្រឹមត្រូវនៃល្វមេ និងល្វខ្វែងរង<br>ង. ពិនិត្យរកមើលការស្រុតដោយមិនប្រក្រតី |
| | ការជ្រាបទឹកចូល | ក. ពិនិត្យរកការជ្រាបទឹកចូល |
| ផ្សេងៗ | | ក. ពិនិត្យមើលការជ្រាបចូលធ្ងន់ធ្ងរ ឬគុណភាពផ្ទៃកខាងក្នុង<br>ខ. ពិនិត្យរកមើលឧស្ម័នពុល ឬក្លិនស្អុយ |

ប្រភព: JASCOMA, 2007

## ២.៩ ការវិនិច្ឆ័យលទ្ធផលនៃការត្រួតពិនិត្យ និងការធ្វើតេស្ត

ជាការចាំបាច់ដែលត្រូវវាយតម្លៃថាតើចាំបាច់ត្រូវធ្វើការជួសជុល ឬកែសម្រួលជាបន្ទាន់ ឬដំណើរការធម្មតា និងការថែទាំមានភាពគ្រប់គ្រាន់ឬអត់ ដើម្បីធានាថាដំណើរការនៃប្រព័ន្ធលូត្រូវបានថែទាំ នៅពេលរកឃើញថាមានភាពខុសប្រក្រតីណាមួយតាមរយៈការសិក្សា និងការវិភាគនោះ។ អ្នកគ្រប់គ្រងទីតាំងគួរតែវាយតម្លៃដោយគិតគូរទៅលើវត្ថុធាតុដើមផលិតលូ អាយុកាលរបស់លូ ទីតាំងកប់ គុណភាពសំណល់រាវ ស្ថានភាពទឹកក្រោមដី និងបរិស្ថាននៅតំបន់នោះ។ល។

លក្ខណៈវិនិច្ឆ័យសម្រាប់ការវិនិច្ឆ័យមានដូចខាងក្រោម៖

- លក្ខណៈវិនិច្ឆ័យសម្រាប់ការឆ្លើយតបបន្ទាន់
- ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ ឬការធ្វើតេស្ត
- លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្ត

### *២.៩.១ លក្ខណៈវិនិច្ឆ័យសម្រាប់ការឆ្លើយតបបន្ទាន់*

ភាពខុសប្រក្រតីទាក់ទងនឹងប្រព័ន្ធលូជាទូទៅ ត្រូវបានរកឃើញតាមរយៈការធ្វើការត្រួតពិនិត្យ ឬរបាយការណ៍ខាងក្រៅ។ គួរចាត់វិធានការភ្លាមៗ នៅពេលដែលមានឧបទ្ទវហេតុបានកើតឡើង។ លើសពីនេះ នៅពេលមានហេតុការណ៍ខាងក្រោមបានកើតឡើង ត្រូវចាត់វិធានការភ្លាម។

- ស្ថានភាពផ្ទៃផ្លូវ៖ ការកើតមានភាពមិនប្រក្រតីដែលអាចធ្វើឱ្យមានកម្រិតនីវ៉ូខុសគ្នានិងនាំឱ្យមានការស្រុត ឬឧបសគ្គសម្រាប់ប្រតិបត្តិការ។
- អណ្តូងលូ៖ ការកើតមានកម្រិតនីវ៉ូទឹកខុសគ្នាដែលអាចនាំឱ្យមានឧបសគ្គដល់ប្រតិបត្តិការ។
- ស៊ីហ្វុងផ្តាប់៖ កម្រិតនីវ៉ូទឹកនៅខាងលើខ្ពស់ជាងខ្លាំង។

### *២.៩.២ ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ ឬការធ្វើតេស្ត*

ការអនុវត្តការធ្វើតេស្តលើគម្លាតរួម និងលូនីមួយៗដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យដោយភ្នែកទទេ។ តារាង ៩ និង ១០ បង្ហាញអំពីលក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្ត។

***តារាង ៩. លក្ខណៈវិនិច្ឆ័យសម្រាប់ការធ្វើតេស្តគម្លាតរួមនៃលូ***

| ផ្នែកនីមួយៗ | | ចំណាត់ថ្នាក់ | | |
|---|---|---|---|---|
| | | (A) | (B) | (C) |
| លូដែលច្រេះ | | ការប៉ះនឹងសរសៃដែក | ការប៉ះជារួម | ផ្ទៃគ្រើម |
| លូផ្ទៀងបញ្ឈរ | ID < ៧០០ មីលីម៉ែត្រ | ≥ ID | ID = ១/២ ID | < ១/២ of ID |
| | ID ៧០០ –១៦៥០ មីលីម៉ែត្រ | ≥ ១/២ of ID | ១/២ ID - ១/៤ ID | < ១/៤ of ID |
| | ID ≥១៦៥០ mm | ≥ ១/៤ of ID | ១/៤ ID - ១/៨ ID | < ១/៨ of ID |

*ប្រភព:* (JASCOMA *ឆ្នាំ* 2007) (ID: អង្កត់ផ្ចិតក្នុង)

*តារាង ១០. លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តសម្រាប់បំពង់លូនីមួយៗ*

<table>
<tr><td colspan="2" rowspan="2">ផ្នែកនីមួយៗ</td><td colspan="5">ចំណាត់ថ្នាក់</td></tr>
<tr><td>(a)</td><td colspan="2">(b)</td><td colspan="2">(c)</td></tr>
<tr><td rowspan="4">លូធ្លុះ</td><td rowspan="2">លូបេតុងអាមេ</td><td>លូប្រហោងធ្លុះ/បាត់ដោយផ្នែក</td><td colspan="2" rowspan="2">ស្នាមប្រេះតាមបណ្តោយលូទំហំ ២មីលីម៉ែត្រ ឬធំជាងនេះ</td><td colspan="2" rowspan="2">ស្នាមប្រេះតាមបណ្តោយលូទំហំតូចជាង ២ មីលីម៉ែត្រ</td></tr>
<tr><td>ស្នាមប្រេះតាមបណ្តោយលូទំហំ ៥ មីលីម៉ែត្រ ឬធំជាងនេះ</td></tr>
<tr><td rowspan="2">បំពង់លូ</td><td>លូប្រហោងធ្លុះ/បាត់ដោយផ្នែក</td><td colspan="2" rowspan="2">ស្នាមប្រេះតាមបណ្តោយលូខ្លីជាង ១/២ នៃប្រវែងលូ</td><td colspan="2" rowspan="2"></td></tr>
<tr><td>ស្នាមប្រេះតាមបណ្តោយលូប្រវែង ១/២ នៃប្រវែងលូ និងវែងជាងនេះ</td></tr>
<tr><td rowspan="2">លូមានស្នាមប្រេះ</td><td>លូបេតុងអាមេ</td><td>ស្នាមប្រេះជុំវិញលូមានទទឹងវែងជាង ៥ មីលីម៉ែត្រ</td><td colspan="2">ស្នាមប្រេះជុំវិញលូ មានទទឹង ២មីលីម៉ែត្រ ឬវែងជាងនេះ</td><td colspan="2">ស្នាមប្រេះជុំវិញលូ មានទទឹងខ្លីជាង ២មីលីម៉ែត្រ</td></tr>
<tr><td>បំពង់លូ</td><td>ស្នាមប្រេះជុំវិញលូមានទទឹង ២/៣ និងវែងជាងនេះ</td><td colspan="2">ស្នាមប្រេះជុំវិញលូ មានទទឹងខ្លីជាង ២/៣ នៃបរិមាត្រលូ</td><td colspan="2"></td></tr>
<tr><td colspan="2" rowspan="2">ចន្លោះតំណលូ</td><td rowspan="2">របូតចេញពីគ្នា (ការដាច់ចេញពីតំណ)</td><td>លូបេតុងអាមេ</td><td>≥ ៧០ មីលីម៉ែត្រ</td><td>លូបេតុងអាមេ</td><td>≥ ៧០ មីលីម៉ែត្រ</td></tr>
<tr><td>បំពង់លូ</td><td>≥ ៥០ មីលីម៉ែត្រ</td><td>បំពង់លូ</td><td>≥ ៥០ មីលីម៉ែត្រ</td></tr>
<tr><td colspan="2">ការជ្រាបទឹកចូល</td><td>សាចចូល</td><td colspan="2">ហូរចូល</td><td colspan="2">បឹតចូល</td></tr>
</table>

*ប្រភព:* (JASCOMA *ឆ្នាំ* 2007)

ការធ្វើតេស្តសម្រាប់គម្លាតរួមបែងចែកជាបីប្រភេទ (A, B និង C)

- ការថយគុណភាពដំណើរការ
- ភាពចាស់ទ្រុឌទ្រោម និង
- ភាពខុសប្រក្រតី

ការបញ្ជាក់ដោយការត្រួតពិនិត្យ និងការធ្វើតេស្តគួរត្រូវបានវាយតម្លៃដូចបង្ហាញនៅក្នុងរូបភាព ២១។




**រូបភាព ២១. រូបបង្ហាញអំពីលក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តលូ**

### *២.៩.៣ លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តលូ*

វិស្វករថែទាំ គួរវិនិច្ឆ័យថា តើត្រូវអនុវត្តវិធានការឆ្លើយតបណាមួយចំពោះលូដែលបានត្រួតពិនិត្យរួច ដោយយោងតាមតារាង ១១ តាមរយៈការដំណើរការ និងថែទាំជាធម្មតា ឬការជួសជុល និងកែសម្រួលជាបន្ទាន់។ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានបង្ហាញនៅក្នុងតារាង ១១ កម្រិតបន្ទាន់ I គឺជាស្ថានភាពមួយដែលចាំបាច់ត្រូវឆ្លើយតបភ្លាមៗ។ កម្រិតបន្ទាន់ II បង្ហាញថា អាចប្រើការឆ្លើយតបធម្មតា និងអនុវត្តវិធានការមូលដ្ឋាននៅក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់។ លើសពីនេះ កម្រិតបន្ទាន់ III បង្ហាញពីការឆ្លើយតបដែលអនុវត្តតាមរយៈប្រតិបត្តិការ និងថែទាំ ព្រមទាំងអនុវត្តការឆ្លើយតបតាមធម្មតាដោយផ្នែក។

*តារាង ១១. លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្តលូ*

| កម្រិតបន្ទាន់ | ប្រភេទ | លក្ខណៈវិនិច្ឆ័យនៃការធ្វើតេស្ត | លក្ខណៈវិនិច្ឆ័យនៃវិធានការ |
|---|---|---|---|
| I | សំខាន់ខ្លាំង | - ទទួលបានលទ្ធផល (A) កាន់តែច្រើន ឬ (a) កាន់តែច្រើនពីការធ្វើតេស្ត | ចាំបាច់ត្រូវចាត់វិធានការភ្លាមៗ |
| II | សំខាន់ល្មម | - ទទួលបានលទ្ធផល (A) មិនសូវជាញឹកញាប់ និង (B) កាន់តែច្រើន ឬ (a) តិច និង (b) កាន់តែច្រើនពីការធ្វើតេស្ត | ត្រូវចាត់វិធានការចាំបាច់តាមរយៈវិធានការបណ្តោះអាសន្ន ហើយវិធានការត្រឹមត្រូវនឹងត្រូវអនុវត្តក្នុងរយៈពេល ៥ ឆ្នាំ |
| III | សំខាន់តិចតួច | - ទទួលបានលទ្ធផល (A), (B) តិចតួច (C) ច្រើន ឬ (a), (b) តិចតួច និង (c) ច្រើនពីការធ្វើតេស្ត | អាចចាត់វិធានការដោយវិធានការបណ្តោះអាសន្ន ប្រសិនបើចាំបាច់ |

## ២.១០ ការរក្សាកំណត់ត្រា និងសកម្មភាពតាមដាន

ដើម្បីឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការធ្វើការត្រួតពិនិត្យ និងការធ្វើតេស្តនៅក្នុងដំណើរការប្រតិបត្តិការ និងការថែទាំបណ្តាញលូឱ្យបានសមស្រប ត្រូវកត់ត្រាលទ្ធផលនៃការធ្វើតេស្ត និងរក្សាទុកតាមទម្រង់ដែលមានបង្ហាញនៅឧបសម្ព័ន្ធ។

### ២.១០.១ សន្លឹកត្រួតពិនិត្យ

នៅពេលធ្វើការត្រួតពិនិត្យ និងការធ្វើតេស្តដូចបង្ហាញនៅក្នុងឧបសម្ព័ន្ធ ២ (ទម្រង់ ១) ត្រូវកត់ត្រាលទ្ធផលនៃការត្រួតពិនិត្យនៅក្នុងសន្លឹកត្រួតពិនិត្យដូចបង្ហាញក្នុងឧបសម្ព័ន្ធ ២ (ទម្រង់ ២)។

### ២.១០.២ សៀវភៅបញ្ជី

ត្រូវប្រើប្រាស់សៀវភៅបញ្ជីសម្រាប់កត់ត្រាការប្រមូលទិន្នន័យនៅទីវាល ដែលរួមមាន ការប្រមូលសំណាក ការវាស់វែង និងការអង្កេត។ ការកត់ត្រាក្នុងសៀវភៅបញ្ជី ត្រូវធ្វើដោយមានគោលបំណងច្បាស់លាស់ ពិតប្រាកដ និងមិនប្រើអារម្មណ៍ផ្ទាល់ខ្លួន ឬពាក្យបច្ចេកទេសផ្សេងៗដែលមិនសមរម្យ ។ ត្រូវកត់ត្រារាល់ព័ត៌មានអំពីសកម្មភាពនៅទីវាលទាំងអស់ក្នុងពេលជំណាលគ្នា និងនៅពេលអង្កេត ឬប្រមូលព័ត៌មាន ដើម្បីកុំឱ្យបាត់ព័ត៌មាន។

សៀវភៅបញ្ជីនេះ ក៏ត្រូវបានប្រើប្រាស់ដើម្បីកត់ត្រាលទ្ធផលការងារប្រចាំថ្ងៃ ដែលអាចយកមកប្រើនៅក្នុងការដំណើរការប្រតិបត្តិ និងថែទាំបណ្តាញលូផងដែរ។ ការកត់ត្រារបាយការណ៍ប្រចាំថ្ងៃមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ២ (ទម្រង់ ៣) និង (ទម្រង់ ៤) សម្រាប់កត់ត្រារបាយការណ៍ប្រចាំខែ។

# ជំពូកទី ៣

# ការថែទាំបណ្តាញលូ

## ៣.១ ការសម្អាតលូ

ដើម្បីប្រតិបត្តិ និងថែទាំប្រព័ន្ធលូប្រមូលទឹកកខ្វក់ឱ្យដំណើរការល្អតាមការគ្រោងទុក វិស្វករថែទាំត្រូវខិតខំសម្រេចឱ្យបាននូវគោលបំណងដូចខាងក្រោម៖

- កាត់បន្ថយចំនួននៃការកកស្ទះតាមលូនីមួយៗ និង
- កាត់បន្ថយចំនួនបណ្តឹងអំពីក្លិនមិនល្អ

ដើម្បីសម្រេចគោលបំណងនេះ ត្រូវសម្អាតលូដោយប្រើប្រាស់ដោយប្រើទឹក ឬម៉ាស៊ីនជាចាំបាច់ និងទៀងទាត់ ដើម្បីដកយកកំណកម្ទេចកម្ទីពីក្នុងលូ ដូចជាខ្សាច់ ល្បាប់ម៉ដ្ឋ ប្រេង ឫសដើមឈើ និងដុំថ្មជាដើម។ កំណកម្ទេចកម្ទីច្រើននៅក្នុងលូកាត់បន្ថយសមត្ថភាពលូ និងអាចធ្វើឱ្យស្ទះលូ ដែលនាំឱ្យមានការហូរហៀរទឹកចេញពីបណ្តាញលូចូលមកផ្លូវ ទីធ្លា និងចូលទៅក្នុងទឹកលើដី។ ឫសដើមឈើ និងការស៊ីរិចរិលក៏អាចធ្វើឱ្យលូខូចផងដែរ។

### *៣.១.១ ឧបករណ៍ និងនីតិវិធីសម្អាត*

ការជ្រើសរើសឧបករណ៍សម្អាតលូអាស្រ័យលើស្ថានភាពរបស់ប្រព័ន្ធលូ គោលបំណងនៃការថែទាំ និងបទពិសោធន៍/ចំណូលចិត្តរបស់វិស្វករទទួលបន្ទុកកិច្ចការថែទាំប្រព័ន្ធលូ។ បញ្ជីឧបករណ៍ដែលត្រូវការសម្រាប់ការថែទាំបណ្តាញលូមានក្នុងឧបសម្ព័ន្ធ ៣។ រដ្ឋបាលក្រុង ស្រុកនីមួយៗដែលមានរៀបចំបណ្តាញលូ គួរតែមានឧបករណ៍ទាំងនោះ និងជួលឧបករណ៍ណាមួយដែលគ្មាននៅពេលត្រូវការ។ ការសម្អាតមាន ៣ ប្រភេទ ដូចជា បច្ចេកទេសសម្អាតដោយប្រើទឹក ប្រើម៉ាស៊ីន និងប្រើសារធាតុគីមី។ នៅក្នុងចំណោមប្រភេទទាំងនេះ ការសម្អាតលូដោយប្រើម៉ាស៊ីន និងទឹក គឺជាវិធីសាស្ត្រដែលមានប្រសិទ្ធិភាពថ្លៃចំណាយទាប ក្នុងការយកចេញនូវសម្ភារៈរូបធាតុផ្សេងៗដែលរាំងស្ទះដល់ដំណើរការត្រឹមត្រូវរបស់លូ។ គោលបំណងនៃការសម្អាត គឺដើម្បីយកចេញនូវសម្ភាររូបធាតុទាំងអស់ដែលតោងជាប់នឹងផ្ទៃខាងក្នុងលូ ដើម្បីឱ្យលូអាចនាំទឹកកខ្វក់បានពេញលេញដោយគ្មានការកំហិតណាមួយដែលអាចនាំឱ្យមានការស្ទះដោយសារតែការថយចុះសមត្ថភាពលូ។

- **ការសម្អាតដោយប្រើទឹក**

ឧបករណ៍បាញ់ទឹកប្រើប្រាស់កម្លាំងទឹកដើម្បីបាញ់សម្អាតលូបានយ៉ាងមានល្អ។ ប្រសិទ្ធភាពនៃការសម្អាត គឺអាស្រ័យលើគោលការណ៍កម្រិតទឹកដែលបង្កើនល្បឿនចរន្តទឹកហូរ និងបង្កើនសមត្ថភាពក្នុងការនាំកករចេញ។ ទំហំកករដែលអាចហូរនាំដោយកម្លាំងទឹកសមាមាត្រទៅនឹងច្បាប់នៃថាមពលទី៦។

បច្ចេកទេសសម្អាតលូដោយប្រើទឹកមានជាច្រើនដូចជាៈ បាល់សម្អាតលូ កង់សម្អាតលូ និងថង់បង្ហូរទឹកដូចបង្ហាញនៅខាងក្រោមៈ

○ *បាល់សម្អាតលូ*

បាល់កៅស៊ូប្រភេទយឺតធម្មតាដែលអាចផ្ទុះទៅតាមកម្រិតខុសៗគ្នានៃការសប់បំប៉ោង។ បាល់ទាំងនោះ ត្រូវបានគេផលិតឡើងមានទំហំអង្កត់ផ្ចិតចាប់ពី ១៥០ មីលីម៉ែត្រ ទៅ ៧៥០ មីលីម៉ែត្រ នៅពេលសប់ខ្យល់ចូលពេញ។ នៅពេលប្រើក្នុងការសម្អាតលូ ដំបូងត្រូវសប់ខ្យល់ចូលបាល់សិន បន្ទាប់មកយកក្រណាត់អំបោះរុំ ហើយដេរចុងក្រណាត់ចូលគ្នា។ ខ្សែធ្វើតេស្តមួយដែលវែងជាងចម្ងាយនៅចន្លោះអណ្តូងលូបន្តិច ត្រូវបិទភ្ជាប់ជាមួយនឹងខ្សែស្រោប។ បាល់ និងខ្សែស្រោបត្រូវតែមានទំហំត្រូវគ្នាជាមួយនឹងលូ។ មិនយូរប៉ុន្មាន បាល់នឹងរុញចូលទៅក្នុងលូ ទឹកកខ្វក់ចាប់ផ្តើមរុញច្រានមកវិញនៅក្នុងអណ្តូងលូ ហើយបន្តឡើងរហូតដល់ពេលមានសម្ពាធខ្លាំងល្មមដើម្បីរុញទឹកកខ្វក់នៅក្រោមបាល់ឱ្យហូរចុះតាមលូ។ ដោយធ្វើជាឆ្នុកបណ្តែតអាចសង្កត់បាន បាល់ជារនាំងមួយល្មមនឹងអាចឱ្យឧបករណ៍បាញ់ល្បឿនទឹកខ្ពស់ បន្តបាញ់ទឹកបុកនៅក្រោមបាល់ និងនៅជុំវិញបាល់ ដូច្នេះវាបើកផ្លូវទឹកឱ្យសម្ភាររូបធាតុអាចហូរបានទាំងអស់ទៅមុខអណ្តូងលូបន្ទាប់។ ប្រសិនបើបាល់ស្ទះមិនអាចហូរទៅមុខបាន បាល់ហូរតាមកម្រិតមួយចាំបាច់ និងហូរទៅមុខទៀត។ មានតែការស្ទះនៅមួយកន្លែងប៉ុណ្ណោះដែលនឹងបញ្ឈប់មិនឱ្យបាល់ហូរទៅមុខបានទៀត គឺជាបណ្តុំឫសដើមឈើ ឬការស្ទះស្រដៀងគ្នាខ្លះដែលសៀតជាប់នៅក្នុងលូ។

ដុំឥដ្ឋ ដុំថ្ម សម្បកដប គ្រឿងបន្លាស់លោហៈ បំណែកលូដែលបាក់ ខ្សាច់ គ្រួស និងសំណល់ភក់កកអាចហូរទៅមុខយ៉ាងងាយស្រួល។ ប្រសិនបើបាល់ឈប់ហូរទៅមុខមួយភ្លែត ការទាញនៅលើខ្សែបាល់ ជាទូទៅ មានគ្រប់គ្រាន់ដើម្បីកំណត់ចលនាបាល់ម្តងទៀត។ ប្រសិនបើលូកខ្វក់ខ្លាំងអាចចងខ្សែបាល់ទៅនឹងកាំជណ្តើរនៅអណ្តូងលូផ្នែកខាងលើ ហើយអាចពន្យឺតដំណើរការបាល់ឱ្យដល់កម្រិតចាំបាច់ដើម្បីទៅដល់អណ្តូងលូក្រោម ដូច្នេះ ត្រូវចំណាយពេលដើម្បីយកល្បាប់ម៉ដ្ឋ និងកំណរកម្ទេចដែលផ្តុំគ្នាមុខបាល់នោះចេញឱ្យអស់។ ការរៀបចំឧបករណ៍បង្ហាញនៅរូបភាព ២២ ។




*រូបភាព ២២. ការតំឡើងឧបករណ៍សម្រាប់ការសម្អាតដោយប្រើទឹកតាមវិធីបាល់សម្អាតលូថង់បង្ហូរទឹក (Flush Bag)*

ឧបករណ៍ដែលមានប្រសិទ្ធភាពខ្លាំងសម្រាប់ការសម្អាតលូតាមផ្នែក ដែលមិនអាចប្រើដងសម្អាតបាន គឺជាថង់បង្ហូរទឹកក្នុងលូ។ ថង់បង្ហូរទឹកគឺជាថង់អំបោះ ឬថង់កៅស៊ូដែលមានបំពាក់ក្បាលទុយោនៅចុងម្ខាង និងក្បាលទុយោតូចនៅចុងម្ខាងទៀត។ ថង់បង្ហូរទឹកត្រូវតភ្ជាប់ជាមួយទុយោបាញ់ទឹក បន្ទាប់មកដាក់នៅចុងខាងក្រោម ចាប់ពីកន្លែងចំណុចដែលមានការបិទផ្លុក។ ថង់បង្ហូរទឹកត្រូវចាក់ទឹករហូតដល់ថង់រីកបិទលូជិត។ សម្ពាធខាងលើកាន់តែកើនឡើងដោយសារការបិទខ្ទប់នេះ ដែលធ្វើឱ្យលែងស្ទះ ហើយលូលែងណែន។

- *កង់សម្អាតលូ (sewer scooter)*

វិធីសាស្ត្រនេះ គឺជាទម្រង់កែលម្អនៃឧបករណ៍សម្អាតលូដែលមានដូយពីរ ខ្សែបញ្ជាមួយ និងកង់ដែលមានរនាំងរឹតជាប់តឹង។ ខុសពីឧបករណ៍សម្អាតលូ កង់សម្អាតលូអាចបញ្ឈប់លំហូរទឹកកខ្វក់បានទាំងស្រុង។ កង់សម្អាតលូដែលមានភ្ជាប់ជាមួយខ្សែបញ្ជា ត្រូវដាក់បន្ទាបចូលទៅក្នុងអណ្តូងលូ ហើយបន្ទាប់មកដាក់ចូលទៅក្នុងបណ្តាញលូនៅខាងក្រោម។ ដុំដូយអណ្តូងលូខាងក្រោមត្រូវបានដាក់បន្ទាបចូលកន្លែងចាប់ពីផ្លូវទៅ ហើយដូយអណ្តូងលូខាងលើដាក់តាមផ្នែកខាងលើនៃអណ្តូងលូ។ នៅពេលប្រើកង់សម្អាតលូក្នុងបណ្តាញលូ វាអាចបញ្ឈប់លំហូរទឹកកខ្វក់ដែលបង្កើននៅផ្នែកខាងក្បាលនៅក្រោយរនាំងកង់សម្អាតលូ។ សម្ពាធធ្វើឱ្យកង់សម្អាតលូធ្វើដំណើរតាមលូរហូតដល់វាប្រមូលផ្តុំកំណករកម្ទេចគ្រប់គ្រាន់ដើម្បីបញ្ឈប់ចលនារបស់កង់សម្អាតលូ។

បន្ទាប់មក ផ្នែកខាងក្បាលអាចបន្តកើនឡើងប្រហែលមួយម៉ែត្រមុនពេលទាញខ្សែបញ្ជាដែលធ្វើឱ្យរនាំងបត់មកវិញ ដូច្នេះអាចឱ្យទឹកកខ្វក់ប្រមូលផ្តុំរុញបុកចូលទៅក្នុងលូខាងក្រោមដែលរុញកំណករកម្ទេចខាងមុខទៅកាន់អណ្តូងលូបន្ទាប់ចាប់ពីកន្លែងយកវាចេញ។ ព្រលែងខ្សែបញ្ជាដោយសម្អាតទឹកកខ្វក់ចេញពីរនាំងកង់សម្អាតលូ ហើយកង់សម្អាតលូរុលទៅមុខម្តងទៀតរហូតដល់កំណករកម្ទេចបញ្ឈប់វាមិនឱ្យទៅមុខ។ ដំណើរការនេះធ្វើដដែលៗរហូតដល់កង់សម្អាតលូទៅដល់អណ្តូងលូខាងក្រោមដែលយកវាចេញ ឬបន្តតាមផ្នែកបន្ទាប់នៃលូ។ ដំណើរការកង់សម្អាតលូមានបង្ហាញនៅក្នុងរូបភាព ២៣។




*រូបភាព ២៣. ប្រតិបត្តិការសម្អាតលូដោយប្រើប្រាស់កង់សម្អាតលូ*

- ## ការសម្អាតដោយប្រើម៉ាស៊ីន

ការសម្អាតដោយប្រើម៉ាស៊ីន ក៏មានបច្ចេកវិទ្យាជាច្រើនផងដែរ ដូចជា ខ្សែពួរ និងបាល់ក្រណាត់ កំណាត់ដងសម្អាតលូ ម៉ាស៊ីនសម្អាតលូ ម៉ាស៊ីនបូមភក់ ម៉ាស៊ីនមានដៃរុញ/ទាញ ដែលមានដងអាចបត់បែនបានក្នុងលូ ឧបករណ៍កៀរសម្អាតលូ ម៉ាស៊ីនបាញ់ទឹក និងឧបករណ៍បឺត។

- ### *ខ្សែពួរ និងបាល់ក្រណាត់*

វិធីទូទៅបំផុតនៃការសម្អាតលូមានអង្កត់ផ្ចិតតូចរហូតដល់អង្កត់ផ្ចិត ៣០០ មីលីម៉ែត្រ គឺប្រើខ្សែពួរ និងបាល់ក្រណាត់។ ដាក់បន្ទះឫស្សីបត់បែនបានចងជាមួយគ្នាចូលទៅក្នុងបណ្តាញលូដោយឱ្យមនុស្សម្នាក់នៅខាងលើ។ ប្រសិនបើចាំបាច់ មនុស្សម្នាក់ទៀតដែលនៅក្នុងអណ្តូងលូដោយប្រើឧបករណ៍សុវត្ថិភាពពេញលេញ វិធានការប្រុងប្រយ័ត្ន និងជំនួយឧបករណ៍សុវត្ថិភាពក្នុងការរុញដងឫស្សី តាមបណ្តាញលូ។ នៅពេលបន្ទះឫស្សីចុងខាងមុខទៅដល់អណ្តូងលូបន្ទាប់ យកខ្សែពួរ និងបាល់ ក្រណាត់ចងនៅចុងម្ខាងនៃចុងខាងក្រោយនៃចម្រៀកឫស្សី។ បន្ទាប់មក មនុស្សម្នាក់ទាញចម្រៀកឫស្សីនៅក្នុងអណ្តូងលូខាងក្រោម ហើយរុញតាមបណ្តាញលូ។ នៅពេលទាញខ្សែ បាល់ក្រណាត់សម្អាតបណ្តាញលូហើយ បញ្ជូនគំនរកម្ទេចកម្ទីដែលប្រមូលផ្តុំទៅកាន់អណ្តូងលូបន្ទាប់ ដែលដាក់ធុងយកចេញ។ ដំណើរការនេះ ធ្វើដដែលៗនៅចន្លោះអណ្តូងលូបន្ទាប់ រហូតដល់បណ្តាញលូទាំងអស់ត្រូវបានសម្អាតរួច។ សកម្មភាពនេះ ទាមទារឱ្យមានការគ្រប់គ្រងដោយប្រុងប្រយ័ត្ន។

- ### *កំណាត់ដងសម្អាតលូ*

ដងទាំងនេះត្រូវបានប្រើប្រាស់ដើម្បីសម្អាតលូតូចៗ។ ជាទូទៅ ដងសម្អាតលូអាចធ្វើពីឫស្សី ឬឈើម៉ៃស័ក ឬដែកស្រាលៗប្រវែងប្រហែលមួយម៉ែត្រ នៅខាងចុងដែលជាមុខតំណដែលនៅជាប់លូ ប៉ុន្តែមិនងាយផ្តាច់ចេញទេ នៅក្នុងអណ្តូងលូ។ កំណាត់ដងសម្អាតត្រូវរុញចុះតាមលូ។ ផ្នែកខាងមុខ ឬខាងចុងនៃដងសម្អាតលូ ជាទូទៅមានបំពាក់ច្រាស កងកៅស៊ូដើម្បីសម្អាត ឬមានផ្លែកាត់ដើម្បីកាត់ និងកម្ចាត់ឧបសគ្គចេញ។ ដងទាំងនេះក៏មានប្រយោជន៍ក្នុងការកំណត់ទីតាំងស្ទះពីអណ្តូងលូក្នុងករណីដែលផ្នែកណាមួយនៃលូមានបញ្ហាផងដែរ។

- ### *ធុងម៉ាស៊ីនសម្អាតលូ*

ធុងម៉ាស៊ីនសម្អាតលូគឺជាឧបករណ៍សម្អាតដោយប្រើម៉ាស៊ីនមួយប្រភេទទៀត។ គេប្រើម៉ាស៊ីននេះដើម្បីយកកម្ទេចកម្ទី ឫសដើមឈើ ប្រេង ឬកម្ទេចកំណរចេញពីបណ្តាញលូមេ។ ម៉ាស៊ីនសម្អាតលូមានបំពាក់ដួយពិសេសដែលទាញធុងពិសេសតាមលូដើម្បីប្រមូលកម្ទេចកម្ទី។ បន្ទាប់មក សម្ភាររូបធាតុដែលប្រមូលបានត្រូវយកចេញពីលូ។

ម៉ាស៊ីននេះមានកម្លាំងខ្លាំង ហើយធ្វើការសម្អាតបានស្អាតល្អដោយមានកំហុសតិចតួចពីការបញ្ហា ដែលអាចប៉ះពាល់ដល់លទ្ធផល។ ដោយសារកន្ត្រៃកាត់ពេញទំហំ និងច្រាសអាចទាញតាមបណ្តាញលូ ការសម្អាតនីមួយៗគួរតែមានភាពហ្មត់ចត់ និងគ្មានសំណល់នៅក្នុងលូមេ។ ដំណើរការធុងម៉ាស៊ីនសម្អាតនេះគឺជាដំណើរការដែលត្រូវការកម្លាំងពលកម្មខ្លាំង ដូច្នេះធុងម៉ាស៊ីន

សម្អាតនេះ ជាទូទៅត្រូវបានប្រើប្រាស់សម្រាប់តែការសម្អាតជាក់លាក់មួយចំនួនប៉ុណ្ណោះ ជាពិសេសការយកកម្ទេចកម្ទីចេញពីលូធំៗ។

- *ម៉ាស៊ីនបូមភក់*

ម៉ាស៊ីននេះមានដៃចូកដោយប្រើខ្សែកាបបន្ទាបចូលទៅក្នុងអណ្តូងលូបើកចំហដោយមានដងស្ទូច និងរ៉កជំនួយ។ នៅពេលទៅដល់បាតអណ្តូងលូ ផ្នែកដៃចូកនេះត្រូវបានបិទ ហើយប្រមូលយកល្បាប់ម៉ដ្ឋ។ បន្ទាប់មក ដៃចូកត្រូវបានលើកឡើងមកលើដី ហើយចាក់ល្បាប់ម៉ដ្ឋនោះចូលក្នុងរថយន្តដឹកជញ្ជូន ឬរ៉ឺម៉កសណ្តោងដោយស្វ័យប្រវត្តិនៅពេលវាបើកចំហវិញ។ គេអាចបិទដៃចូកបានដោយប្រើខ្សែកាប ឬ ស៊ីឡាំងដំណើរការដោយសម្ពាធខ្យល់។ គុណវិបត្តិនៃប្រព័ន្ធនេះគឺវាមិនអាចសម្អាតជ្រុងលូនៅក្នុងអណ្តូងលូបាន។ ពេលខ្លះ កំណកម្ទេចនៅជ្រុងលូអាចមានសភាពរឹងខ្លាំងដែលតម្រូវឱ្យជាប់ចេញ។

- *ម៉ាស៊ីនមានដៃរុញ/ទាញដែលមានដងអាចបត់បែនបានក្នុងលូ*

ម៉ាស៊ីននេះរួមមានម៉ាស៊ីនដែលបង្វិលដងអាចបត់បែនបានដែលចាប់ភ្ជាប់ជាមួយឧបករណ៍សម្អាតដូចជាផ្លែខួងរាងសំប៉ែត ផ្លែខួងរាងគូថខ្យង ឬផ្លែខួងកាំប្រមា និងផ្លែខួងរាងពែង (រូបភាព ២៤)។




*រូបភាព ២៤. ការដំណើរការដងដោយប្រើថាមពល*

ដងបត់បែនបានរួមមានដងដែកថែបដែលមានតំណាវីស។ វារុលតាមអណ្តូងលូបានតាមរយៈទុយោកោង។ ម៉ាស៊ីននេះ រុញដងដែលមានឧបករណ៍ចាប់ភ្ជាប់ជាមួយចុងម្ខាង ហើយចុងម្ខាងទៀតត្រូវបានចាប់ភ្ជាប់ជាមួយម៉ាស៊ីន។ ប្រើដៃដើម្បីរុញដងបង្វិលចូលទៅក្នុងទុយោកោងគៀបអង្គុំជាមួយដងដែលមានដៃវែងសម្រាប់ទប់ដងនៅក្បែរតំណ។ ដោយសារដងត្រូវបានរុញចូលក្នុង

ម៉ាស៊ីនក៏អាចត្រូវទាញចូលទៅជិតអណ្តូងលូដែរ។ ដងត្រូវបានទាញចូល និងទាញចេញយ៉ាងលឿននៅពេលដែលឧបករណ៍ជួបឧបសគ្គដើម្បីកុំឱ្យជាប់គាំង និងបន្ទូរវា។ នៅពេលសម្អាតកន្លែងកកស្ទះហើយ ត្រូវទាញដងចេញតាមរយៈអង្គុំដោយទុកដងឱ្យរុញ ដើម្បីសម្រួលដល់ការដឹកចេញបានលឿន និងងាយស្រួល។ ឧបករណ៍ផ្សេងៗមានបង្ហាញនៅក្នុងរូបភាព ២៥។




*រូបភាព ២៥. ក្បាលមានដង*

- ### *ឧបករណ៍កៀរសម្អាតលូ*

វិធីសាស្ត្រនេះ ត្រូវបានប្រើប្រាស់សម្រាប់លូដែលមានអង្កត់ផ្ចិតធំជាង ៧៥០មីលីម៉ែត្រ។ ឧបករណ៍កៀរសម្អាតលូនេះ ផ្គុំឡើងដោយក្តារឈើដែលមានទំហំតូចជាងបន្តិចបើធៀបនឹងលូដែលត្រូវសម្អាត។ ប្រសិនបើឧបករណ៍សម្អាតលូមិនអាចដាក់បន្ទាបចូលតាមមាត់អណ្តូងលូទេ ចាំបាច់ត្រូវដំឡើងវានៅក្នុងអណ្តូងលូ។ ច្រវ៉ាក់ឧបករណ៍កៀរសម្អាតលូដែលចាប់ភ្ជាប់ជាមួយច្រវ៉ាក់បញ្ជានៅក្នុងអណ្តូងលូដែលត្រូវដាក់បន្ទាបវាចូល ត្រូវភ្ជាប់ជាមួយដុំដូយនៅក្នុងអណ្តូងលូបន្ទាប់ដោយប្រើច្រវ៉ាក់។ បន្ទាប់មក ដំណើរការដុំដូយរុញកំណកកម្ទេចនៅពីមុខឧបករណ៍កៀរសម្អាតលូ។ លំហូរទឹកខាងលើនៅពីក្រោយឧបករណ៍កៀរសម្អាតលូ និងទឹកដែលធ្លាក់ពីខាងលើឧបករណ៍កៀរសម្អាតលូ ក៏នឹងជួយរុញវាទៅមុខដែរ។ ការធ្វើបែបនេះ ធានាថាផ្នែកខាងក្រោម និងចំហៀងលូត្រូវបានសម្អាតល្អ។ កំណកកម្ទេចដែលប្រមូលបានត្រូវកៀរចេញដោយដៃ។

ឧបករណ៍កៀរសម្អាតលូរាងមូល ត្រូវបានប្រើប្រាស់សម្រាប់លូតូចដែលមានអង្កត់ផ្ចិតក្រោម ៣៥០មីលីម៉ែត្រ ដើម្បីសម្អាតតួបណ្តាញលូ។ ឧបករណ៍នេះជាទូទៅហៅថាឧបករណ៍ឌីស ហើយឧបករណ៍ឌីសនេះមានអាចបត់បាន និងធ្វើពីដែក ឬឈើ ដែលខណ្ឌចែកដោយដងដែកប្រហែល ២០០មីលីម៉ែត្រ។

○ ***ម៉ាស៊ីនបាញ់ទឹក***

ម៉ាស៊ីនសម្អាតលូល្បឿនលឿននេះ ប្រើកម្លាំងទឹកបាញ់ខ្លាំងដើម្បីកម្ចាត់ឧបសគ្គ ប្រេងរលាយ គំនរភាគល្អិត និងសម្ភាររូបធាតុផ្សេងទៀតចេញពីប្រព័ន្ធបណ្ដាញលូបង្ហូរទឹកកខ្វក់ ប្រព័ន្ធបណ្ដាញលូបង្ហូរទឹកភ្លៀង និងប្រព័ន្ធបណ្ដាញលូរួម។ ម៉ាស៊ីននេះ រួមបញ្ចូលមុខងារនៃម៉ាស៊ីនមានដៃរុញ/ទាញ និងម៉ាស៊ីនបូមលូ។ ម៉ាស៊ីននេះ មានទុយោបូមទឹកសម្ពាធខ្ពស់ដែលអាចបញ្ជូនទឹកតាមសម្ពាធខុសៗគ្នា រហូតដល់ប្រមាណជា ៨ MPa តាមទុយោបត់បែនបានទៅកាន់ក្បាលបាញ់សម្អាតលូ។ ក្បាលបាញ់ទឹកមានក្បាលបាញ់ទៅមុខមួយ និងក្បាលបាញ់ទៅក្រោយជាច្រើន។ ទឹកសម្ពាធខ្ពស់ដែលចេញពីរន្ធមានល្បឿនខ្ពស់ បំបែក កម្ចាត់ឧបសគ្គ និងបង្ហូរសម្ភាររូបធាតុចេញពីលូ។ លើសពីនេះទៅទៀត តាមរយៈការប្រែប្រួលសម្ពាធផ្សេងៗគ្នាតាមភាពសមស្រប ក្បាលបាញ់ទឹកដើរតួជាឧបករណ៍ខួងបុកបំបែកកំណរកម្ទេចស្ទះរឹងៗផងដែរ។ ទុយោបូម ឬឧបករណ៍បាញ់ខ្យល់ដាច់ដោយឡែកក៏អាចប្រើដើម្បីស្រូបបឺតយកសម្ភាររូបធាតុដែលដាច់ចេញមកផងដែរ។ ជាទូទៅឧបករណ៍ទាំងមូលដាក់នៅលើសាក់ស៊ីរថយន្តធំដែលមានក្បាលម៉ាស៊ីន ឬឧបករណ៍ត្រូវការថាមពលពីម៉ាស៊ីនដាច់ដោយឡែកពីឧបករណ៍បឺត។ ដុំទុយោសម្ពាធខ្ពស់ក៏អូសទាញអ៊ីដ្រូលីកផងដែរ។ រថយន្តដឹកទឹកកខ្វក់ ប្រសិនបើមាន និងប្រសិនគ្មានទេ គឺដឹកទឹកស្អាតមិនទាន់ធ្វើប្រព្រឹត្តិកម្មសម្រាប់ក្បាលម៉ាស៊ីនបាញ់ទឹក។ រថយន្តនេះមានស៊ីទែនទឹកសម្រាប់ដាក់សំណល់ដែលបានយកចេញ និងគ្រប់គ្រងជាមួយគ្នាដើម្បីងាយស្រួលដំណើរការនៅពេលសម្អាតលូ។ សៀវភៅណែនាំអំពីដំណើរការ និងការជួសជុលស្ថានីយ គួរអនុវត្តតាមដោយយកចិត្តទុកដាក់ ដើម្បីប្រើម៉ាស៊ីនឱ្យទទួលបានលទ្ធផលល្អ។

○ ***ឧបករណ៍បឺត***

ឧបករណ៍បឺតបង្កើតសុញ្ញាកាសដែលចាំបាច់ដើម្បីបឺតទាញយកភក់ ភក់រាវ គំនរភាគល្អិត និងសម្ភាររូបធាតុផ្សេងទៀតពីប្រព័ន្ធបណ្ដាញលូបង្ហូរទឹកកខ្វក់ ប្រព័ន្ធបណ្ដាញលូបង្ហូរទឹកភ្លៀង និងប្រព័ន្ធបណ្ដាញលូរួម។ សុញ្ញាកាសដែលបានបង្កើតឡើងនេះ គឺដើម្បីបឺតទាញសម្ភាររូបធាតុពីអណ្ដូងលូជ្រៅៗ ដែលមានជម្រៅចាប់ពី ១ម៉ែត្រ ទៅ ៨ម៉ែត្រ ក្នុងករណីធម្មតាដែលមានជម្រើសក្នុងការបឺតដល់ជម្រៅ ៩ម៉ែត្រ បន្ថែមទៀតដោយមានឧបករណ៍ជំនួយពិសេស។ ឧបករណ៍នេះអាចបំពាក់នៅលើរថយន្ត ឬរទេះរុញ។

ល្បាប់ម៉ដ្ឋ និងភាគល្អិតធ្ងន់ៗដែលកកនៅបាតលូអាចប្រើសម្ពាធខ្យល់បាញ់ក្រឡុក និងធ្វើឱ្យរបូតដោយប្រើប្រាស់សម្ពាធខ្យល់ដោយម៉ាស៊ីនបូមជំនួយ បន្ទាប់មកបឺតដាក់ក្នុងស៊ីទែន។ នៅពេលស៊ីទែនល្បាប់ម៉ដ្ឋពេញ សំណល់រាវបង្ហូរចេញត្រូវបង្ហូរទៅកាន់លូរងទឹកភ្លៀង ឬអណ្ដូងលូនៅក្បែរនោះ បន្ទាប់មកធ្វើដដែលៗរហូតដល់សម្អាតល្បាប់ម៉ដ្ឋអស់ពីអណ្ដូងលូ។ បន្ទាប់មក បង្ហូរល្បាប់ម៉ដ្ឋដែលមាននៅក្នុងស៊ីទែនឱ្យអស់ដាក់នៅកន្លែងចាក់ចោលដែលបានកំណត់ទុកជាមុន។

- ### ការសម្អាតដោយប្រើសារធាតុគីមី

សារធាតុគីមីមួយចំនួន និងវិធីប្រើប្រាស់សារធាតុគីមីទាំងនេះ អាចរកបានដើម្បីសម្លាប់ និងពន្យឺតការលូតលាស់របស់ឫសដើមឈើនៅក្នុងប្រព័ន្ធប្រមូលសំណល់រាវ។ វិធីប្រើប្រាស់រួមមានការប្រើប្រាស់ក្នុងទម្រង់ជាពពុះ ជាម្សៅ និងសារធាតុរាវ។ ឧបករណ៍ពិសេស ត្រូវតែមានជាចាំបាច់សម្រាប់វិធីប្រើប្រាស់ក្នុងទម្រង់ទាំងបីនេះ។ ប្រសិនបើបញ្ហា គឺគ្រាន់តែជាឫសដើមឈើមួយមុខនោះ ការប្រើប្រាស់សារធាតុគីមី គឺជាវិធីដ៏មានប្រសិទ្ធភាពថ្លៃចំណាយបំផុតក្នុងការសម្អាតលូ។ ប្រេងក៏អាចសម្អាតចេញពីលូផងដែរដោយបន្ថែមសារធាតុគីមី ឬដោយការបន្ថែមមីក្រូសារពាង្គកាយ (ការបន្ថែមបាក់តេរីដើម្បីពន្លឿនការបំបែកប្រេង)។ សារធាតុគីមីផ្សេងៗអាចរកបានរួមមាន អង់ស៊ីម អ៊ីដ្រូកស៊ីត វ៉េរនី សារធាតុសម្លាប់ភាវៈមានជីវិត និងសារធាតុធ្វើឱ្យណឺតសម្រាប់ការកម្ចាត់ និង/ឬគ្រប់គ្រងកំណរប្រេង។ ប្រសិទ្ធភាពនៃសារធាតុគីមីជាក់លាក់អាស្រ័យខ្លាំងលើស្ថានភាពជាក់លាក់នៃបញ្ហា និងស្ថានភាពជាក់លាក់នៅតាមទីតាំង។ ក្នុងករណីភាគច្រើន សមាសធាតុទាំងអស់អាចជាវិធីសាស្ត្រចំណាយច្រើន ប្រសិនបើប្រើប្រាស់សមាសធាតុទាំងនេះជាប្រចាំ។ ប្រសិនបើមិនយកប្រេងចេញពីប្រភពទេ វាអាចបង្កើតបញ្ហាបន្ថែមនៅផ្នែកខាងក្រោមនៃស្ថានីយបូមទឹក និងនៅស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់។ ប្បញ្ញត្តិគ្រប់គ្រងប្រេងដោយប្រសិទ្ធភាព គឺជាផ្នែកសំខាន់នៃកម្មវិធីផ្តល់សេវាកម្មណាមួយ។

## ៣.២ ការសម្អាតអណ្តូងលូ

ត្រូវសម្អាតអណ្តូងលូដោយប្រើប្រាស់វិធីសាស្ត្រសមរម្យ និងសមស្របទៅតាមស្ថានភាពជាក់ស្តែងនៅនឹងកន្លែង។

នៅក្នុងអណ្តូងលូ មានគំណរអណ្តូងលូ អណ្តូងលូនៅមុខលូ កំណរខ្សាច់ និងគ្រួស និងបញ្ហាបរិស្ថាន ដូចជា ក្លិនស្អុយ។ អាស្រ័យដោយហេតុផលទាំងនេះ ចាំបាច់ឱ្យមានការសម្អាតឱ្យបានទៀងទាត់។ លើសពីនេះទៀត នៅពេលមានសំរាមធំៗហូរចូល សំរាមនោះត្រូវតែយកចេញភ្លាមៗ។ បើមិនដូច្នោះទេ ការហូរហៀរសំណល់រាវ ការអណ្តែត និងការហើបគម្របលូអាចនឹងកើតឡើង។

ការត្រួតពិនិត្យអណ្តូងលូត្រូវធ្វើជាមួយនឹងការសម្អាតលូ។ ការកាយគ្រួស និងខ្សាច់នៅបាតក្រោមត្រូវធ្វើនៅពេលសម្អាតលូ ហើយស្នាមប្រឡាក់នៅជញ្ជាំងលូត្រូវសម្អាតដោយម៉ាស៊ីនបាញ់សម្ពាធខ្ពស់។

## ៣.៣ ការបោះចោលគ្រួស និងសំណល់ភក់

សំណល់ភក់ដែលប្រមូលពីលូអាចបោះចោលជាមួយគ្រួស និងសំណល់ភក់ពីស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ (ប្រសិនបើមាន)។ ផ្ទុយទៅវិញ សំណល់ភក់ និងគ្រួសក៏អាចចាក់ចោលឱ្យបានត្រឹមត្រូវជាមួយ សំណល់រឹងទីក្រុងផងដែរ។

## ៣.៤ កំណត់ត្រាអំពីការសម្អាតលូ និងការប្រើប្រាស់កំណត់ត្រា

រាល់ប្រតិបត្តិការសម្អាតលូ ត្រូវកត់ត្រាសម្រាប់ជាឯកសារយោងទៅថ្ងៃក្រោយ។ កំណត់ត្រាទាំងនោះរួមមានទិន្នន័យ ឈ្មោះ ឬលេខផ្លូវ ទំហំបណ្តាញលូ ចម្ងាយ និងលេខ ឬអត្តលេខអណ្តូងលូ។ ជាមួយគ្នានេះ ប្រភេទ និងបរិមាណសម្ភាររូបធាតុដែលយកចេញពីលូ លំហូរសំណល់រាវ និងទឹកបន្ថែមដែលប្រើគប្បីកត់ត្រាផងដែរ។ ប្រសិនបើជួបបញ្ហាដោយឡែកណាមួយ គប្បីកត់ត្រាបញ្ហាទាំងនោះ ជាពិសេសទីតាំងជាក់លាក់នៃឧបសគ្គនោះ។ គម្រូទម្រង់កំណត់ត្រា មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៣ (ទម្រង់ ១)។

ប្រសិនបើបំណែកលូដែលបែកបាក់ត្រូវយកចេញ ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យដោយប្រើកាមេរ៉ាទូរទស្សន៍ ហើយត្រូវធ្វើការជួសជុលទៅលើបំណែកលូដែលបានបែកបាក់នោះ។ ការកត់ត្រាទុកទម្រង់ចរាចរណ៍នៅកន្លែងនោះ អាចមានប្រយោជន៍នៅពេលក្រោយ នៅពេលដំឡើងឧបករណ៍នៅទីតាំងនោះ។ គួរតែបង្ហាញអំពីចំណតរថយន្ត (ដូចជានៅលើអណ្តូងលូ) បរិមាណចរាចរណ៍នៅពេលម៉ោងមមាញឹក និងកំណត់ថា ត្រូវការជំនួយពីនគរបាលចរាចរណ៍មុនពេលចូលទៅកន្លែងទីតាំងឬទេ។

# ជំពូកទី ៤

# ការការពារ និងការស្តារសម្បទាបណ្តាញលូ

## ៤.១ ការការពារបណ្តាញលូ

បណ្តាញលូ អាចខូចប្រសិនបើបរិក្ខារផ្សេងៗទៀតដូចជា ទុយោទឹក ឬខ្សែភ្លើង ត្រូវប្រើនៅក្បែរ ឬនៅមុខកាត់លូ។ ជាពិសេស ការប្រែប្រួលដោយសារការកាយដី (គំនរ ដំណក់ទឹកក្រោមដី និង វិធីសាស្ត្រគរ) អាចមានប៉ះពាល់ខ្លាំង។

ដើម្បីកុំឱ្យខូចលូ វិស្វករថែទាំត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូលព័ត៌មានពាក់ព័ន្ធអំពីសកម្មភាពសាងសង់ទាំងអស់ដែលបានគ្រោងទុកនៅជុំវិញបណ្តាញលូ។
- ប្រាប់ពីវិធីសាស្ត្រសាងសង់សមស្របដើម្បីកាត់បន្ថយផលប៉ះពាល់ដល់លូ និង
- ប្រសិនបើចាំបាច់ ស្នើសុំភ្នាក់ងារពាក់ព័ន្ធឱ្យអនុវត្តវិធានការការពារលូមុនពេលចាប់ផ្តើមការងារ។

វិធានការការពារធម្មតាមានដូចខាងក្រោម៖

- ការការពារលូចាស់ (ឧទាហរណ៍មានបង្ហាញនៅក្នុងរូបភាព ២៦)
- ការដាក់ទុយោលូជំនួយបណ្តោះអាសន្ន។
- ការផ្លាស់ប្តូរលូជាមុន។




**រូបភាព ២៦. វិធីសាស្ត្រការពារសម្រាប់លូចាស់**

## ៤.២ ការស្តារសម្បទាលូ

### *៤.២.១ សេចក្តីផ្តើម*

ភាពចាស់ទ្រុឌទ្រោមរបស់លូកើតឡើងនៅលើផ្ទៃទាំងមូល ហើយការជួសជុលក៏ត្រូវការចំណាយពេលច្រើន ដូច្នេះជាចាំបាច់ដែលត្រូវធ្វើការកែលម្អ ឬប្តូរថ្មី និងជួសជុលយោងតាមផែនការ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងការធ្វើតេស្ត។ ការអនុវត្តនេះ នឹងបង្ការមិនឱ្យមានឧបទ្ទវហេតុណាមួយកើតឡើង។

នៅក្នុងទីក្រុងដែលលូភាគច្រើន បានប្រើលើសអាយុកាល ការកែលម្អ ឬប្តូរថ្មី និងការជួសជុលគ្រប់គ្រាន់អាចដោះស្រាយបញ្ហាបន្ទាន់ និងជួយពន្យាររយៈពេលប្រើប្រាស់របស់លូ ដោយកាត់បន្ថយការចំណាយលើប្រតិបត្តិការ និងថែទាំ។ ពាក្យបច្ចេកទេសពីរ គឺការកែលម្អ ឬប្តូរថ្មី និងការជួសជុលមានន័យដាច់ដោយឡែកពីគ្នាដូចខាងក្រោម៖ ការកែលម្អ ឬប្តូរថ្មីមិនបានរាប់បញ្ចូលនៅក្នុងការងារប្រតិបត្តិការ និងថែទាំទេ ប៉ុន្តែរាប់បញ្ចូលនៅក្នុងការសាងសង់ ដោយសារពេលវេលានៃការអនុវត្ត គឺជាចំណុចចាប់ផ្តើមនៃអាយុកាលថ្មីនៃការប្រើប្រាស់លូ ហើយការផ្លាស់ប្តូរនេះ ត្រូវធ្វើឡើងចំពោះទ្រព្យសកម្មរយៈពេលវែង។

- **ការប្តូរថ្មី**

ការប្តូរថ្មីគឺជាការកែលម្អ និងការជំនួសនូវលូដែលមិនបណ្តាលមកពីការពង្រីកប្រព័ន្ធលូបង្ហូរទឹកកខ្វក់ទេ។ ការប្តូរថ្មីរួមបញ្ចូលទាំងការកែលម្អដែលជាការសាងសង់ឡើងវិញ ឬការជំនួសលូដែលមិនទាន់ផុតអាយុកាលប្រើប្រាស់។

- **ការជួសជុល**

ការជួសជុល សំដៅដល់ការប្តូរថ្មីដោយផ្នែក ឬជួសជុលលូដែលខូចខាត។ ការជួសជុលផ្តល់បរិក្ខារ ប៉ុន្តែមិនបង្កើនមុខងាររបស់លូទេ ដោយសារវា មិនបានពន្យាររយៈពេលប្រើប្រាស់លូឡើយ។ ការជួសជុលគ្រាន់តែថែទាំសមត្ថភាព និងអាយុកាលប្រើប្រាស់របស់លូតែប៉ុណ្ណោះ ហើយមិនបង្កឱ្យមានការប្រែប្រួលទ្រព្យសកម្មរយៈពេលវែងឡើយ។

ជារឿយៗ ការបែងចែកភាពខុសគ្នារវាងការងារប្រតិបត្តិការ និងថែទាំ និងការងារសាងសង់មានការលំបាកសម្រាប់ការអនុវត្តការប្តូរថ្មី និងការជួសជុលដោយយោងតាមផែនការ។ ក្នុងករណីមួយចំនួន ត្រូវរៀបចំផែនការការងារទាំងនេះជាកញ្ចប់ទើបជាការប្រសើរ។ ការកែលម្អលើមុខងារប្រើប្រាស់លូដែលមានស្រាប់ ដោយរួមបញ្ចូលសមាសធាតុដែលទាក់ទងនឹងការរៀបចំផែនការ និងគម្រោងសាងសង់ ជាទូទៅហៅថា ការស្តារសម្បទា។ និយមន័យពាក្យគន្លឹះមានបង្ហាញក្នុងតារាង ១២។

***តារាង ១២. និយមន័យពាក្យគន្លឹះ***

| ពាក្យគន្លឹះ | និយមន័យ | ចំណាត់ថ្នាក់ |
|---|---|---|
| ការស្តារសម្បទា ការសាងសង់ឡើងវិញ | រាល់កិច្ចការដែលធ្វើទាំងអស់ដើម្បីកែលម្អមុខងារប្រើប្រាស់របស់ខ្សែលូដែលមានស្រាប់ | គ្រប់វិធានការទាំងអស់ |
| ការជួសជុល | ការជួសជុលលូដែលខូចខាត ឬការកែលម្អ/ប្តូរថ្មីដោយផ្នែកនៃខ្សែលូ | ការវាស់វែងទៅតាមស្ថានភាពលូ |
| ការកែលម្អថ្មី | ការកែលម្អមុខងារប្រើប្រាស់របស់ផ្នែកមួយចំនួនដោយប្រើខ្សែលូដែលមានស្រាប់ | |
| ការប្តូរថ្មី | ការប្តូរលូថ្មីដែលមានមុខងារ និងសមត្ថភាពប្រើប្រាស់ជាមូលដ្ឋានដូចទៅនឹងលូដើម | |
| ការជំនួស | ការជំនួសលូថ្មីដើម្បីពង្រឹងមុខងារ និងសមត្ថភាពប្រើប្រាស់របស់លូ | វិធានការទឹក |
| ការពង្រឹងសមត្ថភាពលូឡើងវិញ | ការតំឡើងលូថ្មីដើម្បីពង្រឹងសមត្ថភាពលំហូររបស់ប្រព័ន្ធលូទាំងមូល | |

### ៤.២.២ វិធីសាស្ត្រស្តារសម្បទាលូ

ដោយយោងតាមវិធីសាស្ត្រចាស់នៃការសម្រាលបន្ទុកលូ ការជំនួសលូថ្មីត្រូវបានធ្វើឡើង ឬបន្ថែមប្រព័ន្ធលូស្របនឹងខ្សែលូចាស់មួយទៀត ដោយជីកដាក់លូតាមបណ្តោយលូចាស់ទាំងអស់ ចំណែកវិធីសាស្ត្រចាស់ក្នុងការស្តារសម្បទាលូ តម្រូវឱ្យជីក និងជំនួសលូចាស់ៗដែលប្រើការលែងបានចេញ (វិធីសាស្ត្រជីក និងជំនួស) វិធីសាស្ត្រស្តារសម្បទាលូដោយមិនជីករណ្តៅ ប្រើលូចាស់ជាទុយោមេសម្រាប់លូ ឬបណ្តាញលូថ្មី។ បច្ចេកទេសស្តារសម្បទាលូដោយមិនជីករណ្តៅកែតម្រូវលូដែលខូច ជាមួយនឹងតម្រូវការនៃការស្តារឡើងវិញ ការរំខាន និងខូចខាតបរិស្ថានតិចជាងវិធីសាស្ត្រជីក និងជំនួស។ វិធីសាស្ត្រស្តារសម្បទាលូដោយមិនជីករណ្តៅរាប់បញ្ចូលទាំង ការបុកទម្លុះបំបែកលូចាស់ដាក់លូថ្មី ការដាក់លូថ្មីក្នុងលូចាស់ ការប៉ះលូដោយដាក់លូថ្មីក្នុងលូចាស់ និងការដាក់លូថ្មីក្នុងលូចាស់ដោយកែតម្រូវមុខកាត់។

- #### ការបុកទម្លុះបំបែកលូចាស់ដាក់លូថ្មី

ការបុកទម្លុះបំបែកលូចាស់ដាក់លូថ្មី គឺជាវិធីសាស្ត្រមួយដែលរុញលូចាស់ចេញ និងបើកចំហដោយប្រើឧបករណ៍បុកទម្លុះ។ នៅពេលបុកទម្លុះបំបែកលូចាស់ដាក់លូថ្មី គេប្រើលូចាស់ជាលូនាំផ្លូវសម្រាប់ស៊កបញ្ចូលក្បាលពង្រីក (ផ្នែកនៃឧបករណ៍បុកទម្លុះ)។ ជាធម្មតា ក្បាលពង្រីកតែងតែទាញដោយដងមានខ្សែ និងម៉ាស៊ីន ដើម្បីពង្រីកកន្លែងដែលមានសម្រាប់ដាក់លូថ្មី ដោយរុញលូចាស់ចេញក្រៅរហូតដល់វាប្រេះបែក។ ឧបករណ៍បុកទម្លុះទាញខ្សែលូថ្មីពីខាងក្រោយវា។ ដំណើរការបុកទម្លុះលូមានបង្ហាញនៅក្នុងរូបភាព ២៧។




*រូបភាព ២៧. ដំណើរការបុកទម្លុះលូចាស់ដាក់លូថ្មី*

## ▪ ការដាក់លូថ្មីក្នុងលូចាស់

ការដាក់លូថ្មីក្នុងលូចាស់ គឺជាវិធីសាស្ត្រដែលគេទទួលស្គាល់ សម្រាប់ការស្តារសម្បទាលូដោយមិនជីករណ្ដៅ។ នៅពេលដំណើរការដាក់លូថ្មីក្នុងលូចាស់ លូថ្មីដែលមានអង្កត់ផ្ចិតតូច ត្រូវដាក់នៅក្នុងលូចាស់។ ជាធម្មតា ត្រូវបិទកន្លែងចំហនៅចន្លោះលូចាស់ និងលូថ្មីដើម្បីកុំឱ្យលេចជ្រាប និងឱ្យលូថ្មី និងលូចាស់ក្លាយទៅជាលូតែមួយ។ ប្រសិនបើទុកកន្លែងចំហនោះចោល លូថ្មីនោះមិនចាត់ទុកជារចនាសម្ព័ន្ធខ្សែលូពេញលេញទេ។ ការបន្តបិទកន្លែងចំហនោះជួយឱ្យលូបិទជិត។ ការបិទតែផ្នែកចុងលូអាចធ្វើឱ្យលូមិនហូរ ឬលេចជ្រាប។ ការដាក់លូថ្មីក្នុងលូចាស់ភាគច្រើនមិនអាចជាចំណុចទទួលទៅកាន់លូបានត្រឹមត្រូវ ដើម្បីធ្វើការស្តារសម្បទាលូទេ។ ក្នុងស្ថានភាពទាំងនេះ ត្រូវជីករន្ធស៊កបញ្ចូលសម្រាប់កំណាត់បណ្ដាញលូនីមួយៗ។ ដោយសារតម្រូវការបែបនេះ ក្នុងការប្រើប្រាស់ភាគច្រើន ការដាក់លូថ្មីក្នុងលូចាស់មិនមែនជាបច្ចេកទេសកាយកប់ពេញលេញទេ។ ប៉ុន្តែ ការកាយដីតិចជាងការកាយដីសម្រាប់វិធីសាស្ត្រចាស់ជីក និងប្តូរ។ លក្ខខណ្ឌបណ្ដាញលូ និងទីតាំង នឹងប្រាប់ពីបរិមាណដីដែលត្រូវកាយ។ វិធីសាស្ត្រដាក់លូថ្មីក្នុងលូចាស់រួមមានវិធីសាស្ត្រតភ្ជាប់បន្តគ្នា វិធីសាស្ត្រតជាកំណាត់ និងវិធីសាស្ត្ររាងគូទខ្យង។ វិធីសាស្ត្រទាំងបី តម្រូវឱ្យតភ្ជាប់លូខ្ទែងរងជាថ្មីដោយកាយ ឬដោយប្រើឧបករណ៍កាត់បញ្ញាពីចម្ងាយ។ នៅក្នុងការតដាក់លូថ្មីក្នុងលូចាស់ ត្រូវតភ្ជាប់ដើម្បី ជាកំណាត់តដែលត្រូវស៊កបញ្ចូលទៅក្នុងលូមេនៅទីតាំងយុទ្ធសាស្ត្រ។ ការដំឡើងនៅចំណុចចូលដូចជាអណ្ដូងលូ ឬរន្ធស៊កបញ្ចូល ត្រូវដោះស្រាយបានជាមួយនឹងការពត់កោងនៃកំណាត់លូត។ ការដំឡើង តាមវិធីសាស្ត្រតជាកំណាត់មានទាក់ទងជាមួយនឹងកំណាត់លូដំឡើងនៅចំណុចចូល។ ការដាក់លូថ្មីក្នុងលូចាស់តាមវិធីសាស្ត្រតជាកំណាត់អាចសម្រេចទៅបានដោយមិនចាំបាច់ធ្វើផ្លូវលំហូរទឹកចាស់ជាថ្មីឡើយ។ ក្នុងការអនុវត្តជាច្រើន លំហូរទឹកចាស់ កាត់បន្ថយការកកិត និងជួយដល់ដំណើរការដំឡើងលូ។ គេប្រើការដាក់លូរាងគូទខ្យង (Spiral-wound slip lining) នៅក្នុងអណ្ដូងលូ ឬចំណុចចូលដោយប្រើចុងតំណភ្ជាប់នៅចុងកំណាត់លូដើម្បីតភ្ជាប់កំណាត់លូ។ បន្ទាប់មកស៊កដាក់លូរាងគូទខ្យងចូលទៅក្នុងលូចាស់ដូចបង្ហាញនៅក្នុង ២៨។




*រូបភាព ២៨. ដំណើរការដាក់លូរាងគូទខ្យង*

- ## ការប៉ះលូដោយដាក់លូថ្មីក្នុងលូចាស់

